ឆ្នាំគ្រូសារ ២០១៧-២០២០

# អ្នកនាំសារ

THE MESSENGER

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១១ | សម្រាប់ខែ តុលា ឆ្នាំ ២០១៩ | តម្លៃលក់ ១០០០រៀល | លេខ #១២៣



រូបភាពៈ ស៊ីអេសស៊ី

## សម្តេច ហ៊ុន សែនៈ

## «ត្រីស្តបរិស័ទត្រូវរួមគ្នាការពារសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គមឱ្យបានគង់វង្ស»


រូបភាព៖ Freepik

### វិចារណកថា

# «តើខ្ញុំជាទូតនៃជំនឿយ៉ាងដូចម្ដេច?»

*ដោយ៖ លី សុវណ្ណា*

ជាសំនួរដែលម្នាក់ៗតែត្រូវឆ្លើយ ក្នុងជីវិតរបស់ខ្លួនដែលជាគ្រីស្ដបរិស័ទ ដែលបានទទួលបេសកកម្មយ៉ាងពិសេស ពីព្រះយេស៊ូគ្រីស្ដ ដែលត្រូវបន្ដនាំដំណឹងល្អទៅមនុស្សទាំងអស់ក្នុងពិភពលោកនេះ។ ការឆ្លើយតាមរយៈទ្រឹស្ដីងាយស្រួលឆ្លើយបំផុត ម្នាក់ៗអាចនិយាយថា ខ្ញុំចង់ ប្រព្រឹត្ដយ៉ាងនេះ យ៉ាងនោះ បង្ហាញធម៌មេត្ដាករុណាដល់មនុស្សតូចតាច យ៉ាងនេះយ៉ាងនោះ។ បើបានឆ្លើយបែបនេះហើយ តើខ្ញុំបានបំពេញហើយឬនៅ? នៅក្នុងខែតុលានេះ សម្ដេចប៉ាប្រ្ហង់ស៊ីស្កូបានអញ្ជើញ និងចាត់ជាខែពិសេសសម្រាប់កិច្ចការប្រកាសដំណឹងល្អ ដែលបានដាក់ចំណងជើងថា «ទទួលអគ្គសញ្ញាជ្រមុជទឹកហើយ និងចាត់ឲ្យទៅ ព្រះសហគមន៍របស់ព្រះគ្រីស្ដ ក្នុងបេសកកម្ម លើពិភពលោកនេះ»។ បានសេចក្ដីថាសម្ដេចប៉ាបចង់ដាស់តឿន និងជំរុញគ្រីស្ដបរិស័ទ ឲ្យយកចិត្ដទុកដាក់ប្រកាសដំណឹងល្អសម្រាប់បងប្អូនឯទៀតៗដែលមិនទាន់បានស្គាល់អំពីព្រះយេស៊ូ។ ក្នុងនោះក៏ចង់រំលឹក អំពីការប្រកាសជំនឿរបស់យើងដោយមានគំរូរបស់សន្ដបុគ្គលជាច្រើន ដូចជា សន្ដីតេរេសា នៃព្រះកុមាយេស៊ូ សន្ដប្រ្ហង់ស៊ីស្កូ នៅអាស៊ីស៊ីអ្នកមានសុភមង្គលផ្សេងៗទៀតផងដែរ។

ជាក់ស្ដែងណាស់កាលពីខែកន្លងទៅ នៅកម្ពុជាយើងបានទទួល អដ្ឋិធាតុរបស់គូស្រករសន្ដល្វីស និងសន្ដីហ្សេលីម៉ាតាំង ដែលបានធ្វើដំណើរ ស្ទើរគ្រប់ព្រះសហគមន៍នៅក្នុងភូមិភាគទាំងបី។ សន្ដសន្ដីទាំងពីរ ក៏ជាគំរូមួយយ៉ាងពិសេស សម្រាប់បងប្អូនគ្រីស្ដបរិស័ទដែលមានជីវិតក្នុងភាពជាគ្រួសារ គូស្វាមីភរិយា។ ចំណុចតូចតាចនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងជាគ្រីស្ដ ដែលយើងអាចប្រកាស និងបង្ហាញពីវត្ដមានរបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ដល់បងប្អូនឯទៀតៗបាន។ មានចំណុចពិសេសដែលសន្ដី និងសន្ដបានប្រណិប័តន៍ និងប្រកាន់ភ្ជាប់ជានិច្ច គឺយកព្រះជាម្ចាស់ជាអាទិភាពក្នុងការរស់នៅ យកចិត្ដទុកដាក់ស្រលាញ់ អប់រំកូន គោរពប្ដី គោរពប្រពន្ធ និងស្រលាញ់បងប្អូនឯទៀតៗ យ៉ាងពិតប្រាកដ។ នេះជាចំណុចពិសេសរបស់សន្ដ និងសន្ដីជាគូស្រករមួយគូនេះមានដែលអាចជាគំរូសម្រាប់យើងជាគ្រីស្ដបរិស័ទសព្វថ្ងៃអាចធ្វើបានដែរ។

នៅមានសន្ដ សន្ដីជាច្រើនទៀត ដែលបងប្អូនអាចយកជាគំរូសម្រាប់ជីវិតផ្ទាល់ខ្លួនក្នុងការប្រកាសដំណឹងល្អអំពីព្រះយេស៊ូដល់បងប្អូន។

ឬមួយវិញទៀត ដូចសន្ដីអ្នកម្ដាយតេរេសា នៃក្រុងកាល់កាតា បានមានប្រសាសន៍ថា៖ «ប្រសិនយើងមិនអាចធ្វើកិច្ចការធំដ៏អស្ចារ្យក្នុងលោកនេះបានទេ។ សូមធ្វើកិច្ចការតូចតាចដោយសេចក្ដីស្រលាញ់ដ៏ធំអស្ចារ្យទៅ»។ ពាក្យនេះមានអត្ថន័យជ្រៅណាស់ ហើយបងប្អូនអាចធ្វើបានតាមលទ្ធភាពរបស់ខ្លួនដោយពោរពេញដោយសេចក្ដីស្រលាញ់ដ៏អស្ចារ្យពីព្រះជាម្ចាស់។

រឿងខ្លះទៀតដែលបងប្អូនអាចធ្វើបានដែរ បើធ្លាប់និយាយដើមរិះគន់ច្រើនចំពោះកិច្ចដែលបងប្អូនធ្វើក្នុងសេចក្ដីល្អបំណងល្អ។ ឈប់រិះគន់ច្រើន ហើយខិតខំបំពេញ កិច្ចល្អឲ្យបានច្រើន នោះក៏ចាត់ទុកថាបានបង្ហាញអំពីវត្ដមានរបស់ព្រះអង្គយេស៊ូផងដែរ។ ការរិះគន់ដើម្បីអភិវឌ្ឍ គឺមិនជាអ្វីទេ តែបើបងប្អូនខ្លះអង្គុយរិះគន់ លោកនេះល្អ លោកនោះមិនល្អ លោកនេះធ្វើត្រូវ លោកនោះធ្វើមិនត្រូវ អ្នកនេះអញ្ចេះ អ្នកនោះអញ្ចុះ ដោយមិនចូលរួមសកម្មភាពជាក់ស្ដែង អនុវត្ដជាក់ស្ដែងក្នុងសហគមន៍បងប្អូនទេ គឺបងប្អូននេះឯងឥតបានការ។

ឬកិច្ចការមួយទៀត ដែលបងប្អូនគួរយកចិត្ដទុកដាក់ គឺការចោលទុកដាក់សំរាមដែលបងប្អូនបានឃើញជារៀងរាល់ថ្ងៃ ដែលមនុស្សជាច្រើនបានចោលពាសវាលពាសកាល គ្មានសណ្ដាប់ធ្នាប់ មិនយកចិត្ដទុកដាក់ សម្អាតចេញតែពីក្នុងបន្ទប់ មុខបន្ទប់សុទ្ធតែសំរាមដដែល នោះ។ បើគ្រប់គ្នាចោលគ្មានរបៀប បងប្អូនអាចចាប់ផ្ដើមពីខ្លួនបងប្អូនផ្ទាល់ ដោយរៀបចំវេចខ្ចប់ ថែកសំរាមតាមប្រភេទច្បាស់លាស់ ត្រឹមត្រូវ ក៏ជាកិច្ចការមួយល្អណាស់ហើយដែរ។ នៅក្នុងប្រទេសយើង តាមអ្នកជំនាញបានឲ្យដឹងថា មានសំរាមប្រមាណ ៣លាន តោនក្នុងមួយឆ្នាំៗ។ ច្រើនណាស់បងប្អូន។ នៅក្នុងរាជធានីភ្នំពេញក៏ហាក់ដូចជាកំពុងខ្វះ ឬស្ទះកន្លែងចាក់សំរាមបណ្ដើរៗហើយ។ រឿងយកចិត្ដទុកដាក់នឹងបរិស្ថានក៏ជាកិច្ចប្រកាសដំណឹងល្អមួយដែរ ដែលយើងបានយកចិត្ដទុកដាក់ស្រលាញ់ស្នាព្រះហស្ថរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ។ សម្ដេចប៉ាប ប្រ្ហង់ស៊ីស្កូ បានមានប្រសាសន៍ថា៖ «យើងម្នាក់ៗទទួលការអញ្ជើញឲ្យចូលរួមយកចិត្ដទុកដាក់ថែរក្សាចំពោះបរិស្ថាន ធម្មជាតិ មិនត្រឹមតែជាពលរដ្ឋដែលមានការទទួលខុសត្រូវប៉ុណ្ណោះទេប៉ុន្ដែក៏ជាអ្នកដើរតាមព្រះគ្រីស្ដផងដែរ»។

មួយទៀតការកាត់បន្ថយ ការប្រើប្រាស់ថង់ប្លាស្ទិក ក៏ជាអ្វីដែលបងប្អូនអាចធ្វើបានចូលរួមទាំងអស់គ្នា ដោយចាប់ផ្ដើមពីខ្ញុំម្នាក់មុនគេ។ សន្ដប្រ្ហង់ស៊ីស្កូ នៃក្រុងអាស៊ីស៊ី មានប្រសាសន៍ថា៖ «សូមចាប់ផ្ដើមដោយធ្វើកិច្ចការដែលចាំបាច់ បន្ទាប់មកធ្វើកិច្ចការដែលបងប្អូនអាចធ្វើទៅបាន ពេលនោះហើយបង្ហាញបងប្អូនថា បងប្អូនកំពុងធ្វើកិច្ចការដែលបងប្អូនគិតថាធ្វើមិនបាន»

សរុបមកវិញ នៅក្នុងខែពិសេស សម្រាប់កិច្ចការប្រកាសដំណឹងល្អ អំពីព្រះគ្រីស្ដក្នុងពិភពលោកនេះ ដែលសម្ដេចប៉ាប ប្រ្ហង់ស៊ីស្កូ បានកំណត់ និងបានអញ្ជើញគ្រីស្ដបរិស័ទត្រូវចូល រិះគិត តើខ្ញុំ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកហើយនោះ ហើយត្រូវបានចាត់ឲ្យចេញទៅប្រកាសដំណឹងល្អនោះ បានបំពេញកិច្ចនេះយ៉ាងដូចម្ដេច នៅកន្លែងដែលខ្លួនរស់នៅ ក្នុងបង្ហាញពីវត្ដមានរបស់ព្រះអង្គយេស៊ូគ្រីស្ដនោះ? ដូចសន្ដីអ្នកម្ដាយតេរេសាមានប្រសាសន៍ថា៖ «ប្រសិនយើងមិនអាចធ្វើកិច្ចការធំដ៏អស្ចារ្យ ក្នុងលោកនេះបានទេ សូមធ្វើកិច្ចការតូចតាច ដោយសេចក្ដីស្រលាញ់ដ៏ធំអស្ចារ្យទៅ»។ ឬមួយតាមគំរូរបស់ សន្ដីហ្សេលីម៉ាតាំង និងសន្ដ ល្វីស បានប្រណិប័តន៍ និងប្រកាន់ភ្ជាប់ជានិច្ច គឺយកព្រះជាម្ចាស់ជាអាទិភាពក្នុងការរស់នៅ ដោយអធិដ្ឋានរាល់ថ្ងៃ យកចិត្ដទុកដាក់ស្រលាញ់ អប់រំកូន គោរពប្ដី គោរពប្រពន្ធ និងស្រលាញ់បងប្អូនឯទៀតៗដោយបម្រើយ៉ាងពិតប្រាកដ។ ម្ដងទៀតសន្ដីអ្នកម្ដាយតេរេសាមានប្រសាសន៍ថា៖ «អធិដ្ឋាននាំឲ្យមានជំនឿ ជំនឿឲ្យមានសេចក្ដីស្រលាញ់ សេចក្ដីស្រលាញ់នាំឲ្យចេះបម្រើ កិច្ចការបម្រើនាំមកនូវសន្ដិភាព ឬសេចក្ដីសុខសាន្ដ»៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ ០៦០/១៩ ព.ម.វ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh




# សម្តេច ហ៊ុន សែន៖ «គ្រីស្តបរិស័ទ ត្រូវរួមគ្នាការពារសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គមឱ្យបានគង់វង្ស»

*សម្តេចតេជោ ហ៊ុន សែន ថ្លែងក្នុងពិធីជួបសំណេះសំណាលជាមួយអ្នកដឹកនាំគ្រីស្តបរិស័ទ។ រូបភាព៖ ហ្វេសប៊ុកសម្តេច ស៊ីអេសស៊ី*

*ដោយ៖ ស៊ីអេសស៊ី*

«គ្រីស្តបរិស័ទត្រូវរួមគ្នាការពារសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់នៅក្នុងសង្គមឲ្យបានគង់វង្ស» នេះជាប្រសាសន៍របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជណាចក្រកម្ពុជា ទៅកាន់ថ្នាក់ដឹកនាំគ្រីស្តបរិស័ទជាង៣០០០នាក់ ក្នុងនោះរួមមាន ថ្នាក់ដឹកនាំ ព្រះវិហារ សមាគម ក្រុមប្រឹក្សាព្រះសហគមន៍នានាទូទាំងប្រទេសកម្ពុជា បានមកជួបជុំគ្នា នៅក្នុងពិធីសំណេះសំណាល និងពិសាអាហារសាមគ្គី ដែលមានសម្តេច ហ៊ុន សែន ជាអធិបតីដ៏ខ្ពង់ខ្ពស់ កាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ រាជធានីភ្នំពេញ។

សម្តេចបានអំពាវនាវថា៖ «គ្រីស្តបរិស័ទត្រូវរួមគ្នាការពារសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គមឲ្យបានគង់វង្ស ពីព្រោះបើមិនមានសន្តិភាពទេ កុំនិយាយពីការរីកចម្រើនខាងសាសនាឲ្យសោះ មានសន្តិភាព យើងអាចធ្វើអ្វីៗបានគ្រប់យ៉ាង»។ សម្តេចតេជោក៏បានអំពាវនាវផងដែរឲ្យគ្រីស្តបរិស័ទ ត្រូវចូលរួមអនុវត្តឲ្យបានខ្ជាប់ខ្ជួន នូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព។ មួយទៀត តាមសហគមន៍ ឬតាមវិហារសាសនា ត្រូវចូលរួមក្នុងយុទ្ធនាការកាត់បន្ថយ និងលុបបំបាត់បញ្ហាគ្រឿងញៀនខុសច្បាប់ផ្សេងៗ។ មួយទៀត ត្រូវយកចិត្តទុកដាក់លើបញ្ហាចរាចរណ៍ ដែលជាបញ្ហាសំខាន់ក្នុងប្រទេសរបស់យើង។ ដូច្នេះក្នុងពេលធ្វើដំណើរនៅលើដងផ្លូវ ត្រូវគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា។ ថ្ងៃនេះ ថ្ងៃស្អែកកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍។

សម្តេចតេជោបន្តថា គ្រីស្តបរិស័ទត្រូវបន្តការយកចិត្តទុកដាក់លើការធ្វើសុខដុមនីយកម្មសាសនា កិច្ចសន្ទនាអន្តរជំនឿ (គ្រីស្តសាសនា និងគ្រីស្តសាសនា) និង មានទំនាក់ទំនងល្អជានិច្ចជាមួយសាសនាដទៃទៀតផងដែរ។ និងចុងក្រោយគឺ ត្រូវបន្តធ្វើការបណ្តុះបណ្តាលធនធានមនុស្សឲ្យបានច្រើនបន្ថែមទៀត ដើម្បីងាយស្រួលចូលរួមចំណែកក្នុងសង្គម និងអភិវឌ្ឍលើវិស័យផ្សេងៗទៀតជាមួយរាជរដ្ឋាភិបាលកម្ពុជា។

សម្តេចតេជោ ហ៊ុន សែន បានបង្ហាញនូវក្តីរីករាយសប្បាយចិត្ត ដែលបានអញ្ជើញចូលរួមសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយបងប្អូនគ្រីស្តបរិស័ទនាពេលនេះ។ នេះជាលើកទី៤ ហើយដែលសម្តេចតេជោ បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងបងប្អូនគ្រីស្តបរិស័ទ ដើម្បីសុខដុមនីយកម្មវិស័យគ្រីស្តសាសនានៅក្នុងប្រទេសកម្ពុជា។

សម្តចតេជោ ហ៊ុន សែន បានមានប្រសាសន៍បញ្ជាក់ថា សាសនាធំៗនៅកម្ពុជាមាន៣ធំៗរួមមាន៖ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ មានឥស្លាមសាសនា និងគ្រីស្តសាសនា។ សាសនាទាំងអស់ អាចរស់នៅជាមួយគ្នាបានដោយមិនមានជម្លោះសាសនានោះទេ ហើយរាជរដ្ឋាភិបាលតែងតែផ្តល់ឱកាសនិងគាំទ្រចំពោះសាសនាទាំងអស់នោះដោយមិនមានការបំបិទសិទ្ធអ្នកកាន់សាសនាអ្វីឡើយ។ កម្ពុជាពិតជាមានមោទនភាពចំពោះសាសនាទាំងអស់ដែលបានរស់នៅមិនមានជម្លោះនឹងគ្នា ហើយក៏មិនមានការវាយប្រហារខាងណានោះទេ។ សម្រាប់ប្រទេសកម្ពុជាបងប្អូនជឿទៅលើសាសនាមួយណា គឺជាសិទ្ធសេរីភាពរបស់បងប្អូន។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ទៀតថា សាសនាទាំងអស់នៅក្នុងប្រទេសកម្ពុជាបានរស់ឡើងវិញក្រោយពីរបបប្រល័យពូជសាសន៍ ប៉ុល ពត បានដួលរលំ។

តាមរបាយការណ៍របស់ឯកឧត្តម ទេសរដ្ឋមន្ត្រី ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា បានឱ្យដឹងថា បច្ចុប្បន្នប្រជាពលរដ្ឋខ្មែរដែលបានជឿលើព្រះយេស៊ូគ្រីស្ត មានចំនួនសរុប ១១៩,៤០២នាក់។ លោកបន្តថា គ្រីស្តសាសនាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយពង្រឹង និងអប់រំសីលធម៌ ចរិយាធម៌សង្គម និងចូលរួមយ៉ាងសកម្មក្នុងការកសាង និងអភិវឌ្ឍសង្គមកម្ពុជាឱ្យមានសុខសន្តិភាព ស្ថិរភាពរស់នៅប្រកបដោយភាពថ្លៃថ្នូរ និងសុខដុមរមនាជាមួយគ្នា ជៀរចាកផុតពីការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និន្នាការជំនឿសាសនា អំពើប្រទូសរ៉ាយ អំពើហិង្សាផ្សេងៗ ទាំងនៅក្នុងគ្រួសារ សហគមន៍ ក៏ដូចជានៅក្នុងសង្គមជាតិទាំងមូល។

ទាក់ទងនឹងការអំពាវនាវរបស់សម្តេចនាយករដ្ឋមន្ត្រី អំពីសុខដុមរមនាសាសនា លោក បូរ៉ាវុធ តំណាងគ្រីស្តបរិស័ទកាតូលិក មកពីបាត់ដំបងបានឲ្យថា ពិតប្រាកដ១០០% មានសុខដុមរមនា ខាងសាសនា ក្នុងតំបន់របស់លោក គឺមានសេចក្តីសុខ និងគ្មានវិវាទអ្វីនោះទេ។ ចំពោះទំនាក់ទំនងជាមួយអាជ្ញាធរទៀតសោត គឺគ្មានបញ្ហាអ្វីសោះឡើយ។ លោកបានបញ្ជាក់ថា ពេលយើងសុំច្បាប់ប្រារព្ធបុណ្យទានម្តងៗ គឺអាជ្ញាធរតែងជួយគាំពារយើងជានិច្ច។ លិខិតស្នាមនានាទាក់ទងនឹងបេសកជនសាសនទូត មានការធានា ត្រឹមត្រូវតាមច្បាប់ អាជ្ញាធរតែងយកចិត្តទុកដាក់ គាំពារជានិច្ចផងដែរ។ ចំពោះកិច្ចសន្ទនាអន្តរជំនឿ ឬអន្តរសាសនា គឺព្រះសហគមន៍ក្នុងភូមិភាគបាត់ដំបងបានយកចិត្តទុកដាក់យ៉ាងខ្លាំង និងមានទំនាក់ទំនងល្អជានិច្ច។

ក្នុងពិធីដ៏វិសេសវិសាលនោះ តំណាងថ្នាក់ដឹកនាំគ្រីស្តបរិស័ទ មានព្រឹទ្ធាចារ្យ គ្រូគង្វាល និងបូជាចារ្យ បានប្រកាសគោលជំហរយ៉ាងឱឡារិកគាំទ្រជានិច្ចនិងទាំងស្រុង ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចហ៊ុន សែនជានាយករដ្ឋមន្ត្រី ដែលសម្តេចបានខិតខំអស់ពីកម្លាំងកាយចិត្ត ដើម្បីពលរដ្ឋកម្ពុជាមានស្នាមញញឹម រីកចម្រើន និងសន្តិភាព។ ព្រមទាំងបានអធិដ្ឋានសូមព្រះជាម្ចាស់ថែរក្សា និងប្រទានពរដល់មុខរាជរដ្ឋាភិបាលមានសុខភាពល្អ និងទទួលបានជោគជ័យជានិច្ច៕




*សម្តេចតេជោ ហ៊ុន សែន ថតរូបអនុស្សាវរីយជាមួយថ្នាក់ដឹកនាំ និងតំណាងគ្រីស្តបរិស័ទក្នុងពិធី។ រូបភាព៖ ស៊ីអេសស៊ី*



*លោកបូជាចារ្យ សួន ហង្សលី ទទួលស្វាគមន៍ សម្តេចតេជោ ហ៊ុន សែន។ រូបភាព៖ ស៊ីអេសស៊ី*



*លោក ដួង សាវង់ និងតំណាងគ្រីស្តបរិស័ទឡើងថ្លែងក្នុងពិធី។ រូបភាព៖ ស៊ីអេសស៊ី*

# សិប្បកម្មតម្បាញ ក្រមាខ្មែរ



*ដោយៈ ផល សុផានិត*

ក្រមាគឺជាសម្ភារប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ តាំងពីបុរាណកាលមកដល់សព្វថ្ងៃ។ ក្រមាត្រូវបានត្បាញឡើងដោយអំបោះឆ្អែ រំលេចជាក្រឡាគោម ឆ្លាស់ពណ៌លាយគ្នាជាទីចាប់អារម្មណ៍របស់អ្នកប្រើប្រាស់។ ពីបុរាណមក តម្បាញក្រមាជាលក្ខណៈសិប្បកម្មប្រពៃណីធ្វើដោយដៃ ប៉ុន្តែសព្វថ្ងៃការងារប្រើកម្លាំងច្រើនត្រូវកាត់បន្ថយមកជាម៉ាស៊ីនវិញ ដើម្បីបំពេញតម្រូវការទីផ្សារ។

ស្ថិតនៅជាយរាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខមួយ ភូមិជ្រោយអំពិលសង្កាត់ក្បាលកោះខណ្ឌច្បារអំពៅរាជធានីភ្នំពេញ ត្រូវបានគេស្គាល់ជាទូទៅថា ជាតំបន់ត្បាញក្រមាដ៏ធំមួយ។ ប្រជាជនលើសពីពាក់កណ្តាលនៃភូមិនេះ ប្រកបរបរសិប្បកម្មត្បាញក្រមា។

អ្នកស្រី បាន សុផល ជាសិប្បិនីក្រមា ក្នុងចំណោមអ្នកតម្បាញជាច្រើន ដែលបើកសិប្បកម្មត្បាញក្រមា ឲ្យដឹងថា អ្នកស្រី បានក្លាយជាអ្នកត្បាញក្រមាបន្តវេនពីឪពុកម្តាយរហូតមកដល់សម័យវិវដ្តនៃការត្បាញក្រមានេះ។

អ្នកស្រី បាន សុផល៖ «ពីមុនមកយើងចាប់ផ្តើមដំបូងគេ គេត្បាញគីបណ្តាក់ បន្ទាប់មកគីម៉ាស៊ីនដែរតែយើងជាន់ជើង ឥលូវយើងចុចភ្លើងដោយសារ វាលឿន ដែលយើងធ្វើវាលឿនទាន់តម្រូវការ។ អ្នកផ្សារអូឡាំពិកគេមកទទួលពីខ្ញុំវិញ និងខ្លះទៀតមកតាមខេត្ត ឬក៏មានអ្នកមកទិញផ្ទាល់នៅដល់ផ្ទះយើងចឹង»។



*តម្បាញក្រមាជាលក្ខណៈសិប្បកម្មប្រពៃណី ត្រូវបានជំនួសដោយគ្រឿងម៉ាស៊ីនវិញ។ រូបភាពៈ ស៊ីអេសស៊ី*

អ្នកស្រី ងួន សុផានី ជាអ្នកលក់ក្រមាក្នុងផ្សារធំថ្មី រាជធានីភ្នំពេញឲ្យដឹងថា៖ «ភ្ញៀវទេសចរណ៍បរទេសនិយមក្រមាជាវត្ថុអនុស្សាវរីយ៍។ តែក្នុងពេលបច្ចុប្បន្ននេះ សម្អាងការផ្សេងៗបានចាប់អារម្មណ៍ យកក្រមាធ្វើជាវត្ថុសម្រាប់ភ្ញៀវទៅចូលរួមមង្គលការ និងហាងលក់សម្លៀកបំពាក់ខ្លះ ក៏គេទិញក្រមាអំបោះយកទៅកាត់ជាសម្លៀកបំពាក់ផងដែរ។ ចំណែកប្រជាជនធម្មតា គេនិយមក្រមាអំបោះសម្រាប់ប្រើប្រាស់ក្នុងគេហដ្ឋានតែប៉ុណ្ណោះ»។

ក្រមាខ្មែរត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយដោយរដ្ឋាភិបាល បង្កើតឲ្យមានកម្មវិធីមួយចំនួនកាលឆ្នាំកត្តកម្មពិភពលោក ដោយមានប្រជាជនខ្មែរជាច្រើនពាន់នាក់ចូលរួមត្បាញក្រមានៅទីលានព្រះសុមេរុ។ ហើយក្រមាក៏ត្រូវបាន សិល្បៈករ សិល្បៈការិនី បាននាំគ្នាកាត់សម្លៀកបំពាក់ប្រពៃណី និងប្រើប្រាស់ជាទូទៅ។

បន្ទាប់ពីការវិវត្តន៍នៃការត្បាញក្រមាពីដៃ មកជាម៉ាស៊ីនដូចសព្វថ្ងៃ អ្នកស្រី បាន សុផល បានឲ្យដឹងដែរថា ដំណាក់កាលផលិតក្រមាខ្លះក៏ត្រូវបានផ្លាស់ប្តូរដែរ ដើម្បីឲ្យផលិតផលក្រមាផលិតបានលឿន និងប្រើប្រាស់កម្លាំងពលកម្មតិចជាងមុន ។

អ្នកស្រីបន្ថែមថា កាលពីមុន គីតម្បាញមួយត្រូវការមនុស្សម្នាក់ ហើយត្រូវការពេលវេលាយូរ ប៉ុន្តែដល់ពេលមានម៉ាស៊ីនយើងប្រើកម្លាំងមនុស្សតិចជាងមុន និងផលិតផលទទួលបានច្រើនជាង។ ម៉ាស៊ីនគីតម្បាញនៅក្នុងសិប្បកម្មរបស់អ្នកស្រីមានចំនួនទាំងអស់ ៣០ ដែលត្រូវការមនុស្សមើលតែ១០នាក់ប៉ុណ្ណោះ។

អ្នកស្រី បាន សុផល បានបន្តថា ក្នុងមួយថ្ងៃមិនអាចកំណត់បានចំនួនជាក់លាក់នោះទេ តែបើគិតជាមធ្យមវិញ បានប្រមាណពី៥០០ ទៅ៦០០ ក្រមាក្នុងមួយថ្ងៃ។ សិប្បកម្មរបស់អ្នកស្រីផលិតតែក្រមាប្រើប្រាស់ក្នុងផ្ទះប៉ុណ្ណោះ ដែលមានទំហំបណ្តោយ១ម៉ែត្រ២តឹក និងទទឹងកន្លះម៉ែត្រ។

អ្នកស្រី បាន សុផល «ពីមុនមក ខ្ញុំផលិតអំបោះពីរប្រភេទ ១ពីនីឡុង ដែរប្រភេទនេះគេមិននិយមប្រើទៅជាអាវប៉ុន្តែប្រហែលជា ២ទៅ៣ឆ្នាំក្រោយនេះ ខ្ញុំប្រើជាអំបោះខ្មែរយើងវិញ បានចាប់ផ្តើមដើរ ដែរគេយកវាទៅកាត់អាវគេយកទៅដេរជាម្ជូក ជាកាបូប និងចែកកាដូរការ»។

វត្ថុធាតុដើមសម្រាប់ផលិតក្រមាត្រូវបាននាំចូលពីប្រទេសថៃ ដែលមានជាអំបោះឆៅ និងសសៃនីឡុង។ រីឯគ្រឿងម៉ាស៊ីនតម្លើងក្នុងកី គឺនាំចូលមកពីប្រទេសថៃ ដែលមានតម្លៃ៤០០ដុល្លារក្នុងមួយឈុត។

ទីផ្សារក្រមាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ មានសន្ទុះគាំទ្រខ្លាំង ប៉ុន្តែអ្នកស្រី បាន សុផល បានអះអាងថា ការជាវក្រមាក៏មានតាមរដូវកាលរបស់វាដែរ។ អ្នកស្រី បាន សុផល បន្ថែមថា ចាប់ពីខែមករា ដល់ ឧសភាជាពេលវាលារដូវច្រូតកាត់ និងពិធីមង្គលផ្សេងៗ ក្រមាលក់ដាច់ជាងគេ។ ក្រៅពីនោះ ពិបាកលក់បន្តិចហើយ។

អ្នកស្រី បាន សុផល បន្តថា ការត្បាញក្រមារបស់អ្នកស្រី ជាសិប្បកម្មលក្ខណៈគ្រួសារ ជាសិប្បកម្មប្រើកម្លាំង អ្នកស្រីមិនបានគិតដល់ការនាំចេញទៅបរទេសនោះទេ។ អ្នកស្រីបន្តអំពាវនាវឲ្យមានការគាំទ្រផលិតផលក្រមាខ្មែរ ដើម្បីបន្តឲ្យរបរហត្ថកម្មរបស់ដូនតានេះ រស់រានមានជីវិតបន្តទៀត៕





*កម្មករ និងកម្មការិនីបំពេញការងារក្នុងសិប្បកម្មត្បាញក្រមាភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅរាជធានីភ្នំពេញ។ រូបភាពៈ ស៊ីអេសស៊ី*

# សំពត់ហូលខ្មែរ កំពុងមានទីផ្សារចង្អៀត

## សិប្បករហូលផាមួងមួយចំនួននៅក្នុងឃុំតាយ៉ាប ស្រុកព្រៃកប្បាស ត្អូញត្អែរអំពីចំណូលក្នុងវិស័យនេះធ្លាក់ចុះ ហើយស្ទើរតែបាត់បង់គ្មានអ្នកចង់ត្បាញទៀតឡើយ។


*ផលិតផលសូត្រដែលបានដាក់តាំងលក់លើទីផ្សារ។ រូបភាព៖ សហការី*

*ដោយ៖ ផល សុផានិត*

ស្ថិតនៅក្រោមផ្ទះ ក្នុងភូមិត្រពាំងស្តុក ស្រុកព្រៃកប្បាស ខេត្តតាកែវ លោក គង់ សុផល កំពុងអង្គុយគោះកីតម្បាញសំពត់ហូល ដែលមានគោមក្បាច់ផ្កាចម្រុះ។ ជាគ្រូបង្រៀនក្នុងវិទ្យាល័យមួយក្នុងឃុំ លោក គង់ សុផល ឆ្លៀតពេលទំនេរពីការងារជាគ្រូបង្រៀន ជួយភរិយាត្បាញហូល។

លោក គង់ សុផល បានឲ្យដឹងថា លោកសប្បាយរីករាយក្នុងចិត្ត ដែលបានបន្តកេរ្តិ៍មរតកដូនតាមួយនេះ ប៉ុន្តែលោកគ្រូ អក្សរសិល្បខ្មែរថ្នាក់ទី៩រូបនេះ មិនសប្បាយចិត្តនោះទេ ដែលសំពត់សូត្រនេះ មានទីផ្សារតូចចង្អៀត។

លោកគង់ សុផលថ្លែងថា៖ «ដល់ពេលដែលយើងធ្វើបានហើយ គ្មានទីផ្សារ ដូចនេះផលិតផលដែលខំរក្សាកេរ្តិ៍ដូនតាមួយនេះ គ្មានន័យ តែយើងមិនដឹងថា គួរតែធ្វើអ្វីនោះ។ ផលិតផលយើង អ្នកប្រើក្នុងស្រុកមិនប្រើផង នាំចេញក៏គ្មានទៀត ដូច្នេះមិនដឹងថាធ្វើយ៉ាងម៉េចដែរ គ្រាន់តែចេះតែធ្វើជាបន្តទៀតទៅ គ្រាន់តែបានតិចឬច្រើនប៉ុណ្ណោះ»។

ចំណែកបុរស ត្បាញហូល ម្នាក់ទៀតដែលស្ថិតនៅក្នុងភូមិនេះដែរ លោក ឈិន សារី លើកឡើងថា តម្បាញជាការងារទំនេរពីស្រែចម្ការ។ លោក សារី ប្រហែលជាមនុស្សប្រុសតែម្នាក់គត់ដែលនៅផ្ទះគោះកីតម្បាញជាប្រចាំ ខណៈពេលដែល ស្រ្តីៗនៅក្នុងគ្រួសាររបស់លោក សម្រេចចិត្តបោះបង់ចោល កីតម្បាញ និងប្រែចិត្តទៅធ្វើការងារក្នុងរោងចក្រ ដោយសារតែទីផ្សារហូល តូចចង្អៀត និងមានតម្លៃទាបមិនសមនឹងកម្លាំង ពេលវេលានៃកិច្ចការតម្បាញ។

លោក ឈិន សារី និយាយថា សមាជិកក្នុងគ្រួសាររបស់លោក ធ្វើការងារក្នុងរោងចក្រមិនសូវហត់ និងងាយស្រួលទទួលបានបាក់ក្រម្រៃ។ លោកនិយាយទៀតថា យ៉ាងណាក៏ដោយ លោកនៅតែស្រលាញ់ ចាប់អារម្មណ៍ និងចង់រក្សាមុខរបរ ជាកេរ្តិ៍មរតកដូនតាមួយនេះ ឲ្យបានគង់វង្ស ដើម្បីបន្តឲ្យកូនចៅជំនាន់ក្រោយបន្តទៀត ទោះបីជានៅពេលនេះតម្លៃហូលនៅទីផ្សារធ្លាក់ចុះក៏ដោយ។

លោក ឈិន សារី៖ «ឥឡូវស្រីៗគេមិនសូវ នៅត្បាញទេ ព្រោះថាសំពត់ឥឡូវ ហូលពេលនេះថោកពេក ប្រុសៗនេះនៅមើលកូនចៅខ្លះទៅ នៅត្បាញខ្លះចឹងទៅ។ ម្នាក់ៗគិតតែបោះចោលទៅ តើនៅពេលអនាគតទៅមុខទៀតនោះ គ្មានអ្នកត្បាញហូល ព្រោះនេះជាកេរ្តិ៍មរតកតាំងពីដើមមក»។


*ផលិតផលសូត្រខ្មែរ។ រូបភាព៖ សហការី*

ពិតណាស់ប្រជាពលរដ្ឋ ដែលពេញកម្លាំង ក្នុងប្រទេសកម្ពុជា ដោយឡែកអ្នកភូមិត្រពាំងស្តុក បានចាកចេញស្ទើរតែស្ងាត់ភូមិទៅហើយ ទៅធ្វើការងារនៅតាមរោងចក្រ និងនៅក្រៅប្រទេស ដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់គ្រួសារ។ ភូមិនេះ កាលពីដើមយើងធ្លាប់លឺស្នូរ គោះកីត្បាញ តែពេលនេះប្រែជាស្ងប់ស្ងាត់។

អ្នកស្រី ជា ស៊ីវអាន ប្រធានសហគមន៍ហូលផាមួងខ្មែរ ឃុំតាំងយ៉ាប ទទួលស្គាល់ថា ប្រជាពលរដ្ឋប្រហែល៧០%ដែលជាសមាជិករបស់សហគមន៍ បានបោះបង់ចោលមុខរបរត្បាញនេះ ដោយសារតែមុខរបរមួយនេះ គ្មានទីផ្សារទូលំទូលាយ និងខ្វះការគាំទ្រពីស្ថាប័នពាក់ព័ន្ធ។

ក្នុងឆ្នាំ២០០៩ កាលពីពេលដែលបង្កើតសហគមន៍ដំបូង មានប្រជាជនក្នុងឃុំ ជាង១០០០គ្រួសារ បានចូលជាសមាជិកសហគមន៍។

អ្នកស្រី ជា ស៊ីវអាន៖ «សមាជិករបស់សហគមន៍នេះបាត់បង់បន្តិចម្តងៗ នៅសល់តែ៣០%ទេ ដែលនៅត្បាញហូលនេះ។ នៅសល់ទី១ ដោយសារ គាត់អាយុច្រើនមិនអាចទៅធ្វើការងារឆ្ងាយបាន ទៅធ្វើការងារនៅក្រៅប្រទេស ទៅធ្វើការងាររោងចក្រ គាត់នៅតែព្យាយាមធ្វើមុខរបរគាត់ពីមុនមក គាត់ចេះតែធ្វើទៅ ទោះបីជាចំណេញតិចឬច្រើន គាត់ចេះតែធ្វើទៅ គាត់គ្មានមុខរបរធ្វើក្រៅពីនេះ បើសិនជាគាត់មានមុខរបរធ្វើក្រៅពីនេះ ប្រហែលជាគាត់ឈប់ធ្វើដែរ»។

អ្នកស្រី ស៊ីវហ៊្គិច ជាសិប្បិនី ក្នុងភូមិនេះដែរ បានឲ្យដឹងថា នៅពេលបច្ចុប្បន្ននេះតម្បាញហូល ជាការងារពិបាកណាស់។ កូនៗរបស់អ្នកស្រីមិនចូលចិត្តធ្វើការងារនេះទេ។

អ្នកស្រី ស៊ីវហ៊្គិចបន្តថា៖ «កូនៗរបស់ខ្ញុំមិនទាន់ចេះត្បាញនោះទេ អាយុម្ភៃជាងហើយ ពួកវាមិនទាន់ចេះត្បាញនោះទេ កូនខ្ញុំមិនចង់ធ្វើនោះទេ ហើយខ្ញុំក៏អស់សង្ឃឹមដែរ ខ្លាចវាបាត់ស្នាដៃខ្មែរយើងនេះដែរ បើសិនជាមានអង្គការណាមួយ លើកតម្កើងតម្លៃហូលខ្មែរយើងនេះវិញ ប្រហែលជាក្មេងៗវាងាកមកធ្វើការងារត្បាញហូលនេះវិញ។ មិនចង់ឲ្យបាត់កេរ្តិ៍ដំណែលខ្មែរយើង»។

ប្រជាជននៅក្នុងឃុំតាំងយ៉ាប គ្មានចំការដាំមន និងចិញ្ចឹមដង្កូវនាងទេ ដោយសារខ្វះកំលាំងពលកម្ម ហើយប្រជាជនភាគច្រើនគាត់ធ្វើស្រែតែប៉ុណ្ណោះ។ និយាយពីវត្ថុធាតុដើម អ្នកតម្បាញបានឲ្យដឹងថា សូត្រឆៅដែលយកមកនោះ គឺនាំចូលពីប្រទេសថៃ មួយគីឡូថ្លៃ២០ដុល្លារអាមេរិក បើបូករួមទាំងល័ក្សទៀត ថ្លៃដើមអាចចូលដល់៣០ដុល្លារក៏មាន។

លោក ស៊ីវ វុទ្ធី ប្រធានក្រុមប្រឹក្សាឃុំតាំងយ៉ាប បានឲ្យដឹងថា ការងារត្បាញរបស់អ្នកឃុំតាំងយ៉ាប មានសន្ទុះទីផ្សារខ្លាំង ក្នុងពេលឆ្នាំ ១៩៩០ ដល់ឆ្នាំ២០០៨ នឹងទទួលបានប្រាក់ចំណេញខ្ពស់ តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ នៅពេលដែរលវត្ថុធាតុដើម នាំចូលពីប្រទេសជិតខាងមានតម្លៃខ្ពស់ ប្រាក់ចំណេញពីសិប្បកម្មហូលកាន់តែតិចទៅៗសម្រាប់ប្រជាសិប្បករ។

លោក ស៊ីវ វុទ្ធី «កត្តាសំខាន់ទី១ ដោយសារតែវត្ថុធាតុដើមគឺយើងនាំចូល ទី២ផលិតផលសម្រេចរបស់យើង គឺមិនមែនអត់ទីផ្សារនោះទេ ប៉ុន្តែវាក្រទីផ្សារ ។ ក្រោយឆ្នាំ២០០៨មកយើងហាក់មានការប្រែប្រួល វាធ្វើឲ្យប្រជាពលរដ្ឋយើងពិបាកក្នុងការស្វែងរកទីផ្សារ ហើយទីផ្សារដែរមានសព្វថ្ងៃនេះ គឺតាមរយៈទីផ្សារកំណត់ឲ្យ មានន័យថាបើគេចង់បានក្បាច់អី ម៉ូតអី គេបញ្ជាទិញតាមឈ្មួញកណ្តាល»។

អ្នកត្បាញហូលភាគច្រើន បាននិយាយដូចគ្នាថាតម្លៃហូល មិនអាចកំណត់បាននោះទេ គឺអាស្រ័យទៅតាមឈ្មួញកណ្តាល ត្រូវទៅតាមសំពត់ហូល ទឹកដៃត្បាញនឹងគុណភាពនៃសំពត់ហូល។ អ្នកត្បាញបានបញ្ជាក់ថា តម្លៃហូលជាមធ្យម ចាប់ពី២៨០០០០រៀល ដល់ ៤០០០០០រៀល ឬឡើងដល់៨០០០០០រៀល ក្នុងមួយក្បិន។ រីឯតម្បាញក្នុងមួយក្បិនត្រូវការពេលយ៉ាងតិចណាស់១០ថ្ងៃ។

កញ្ញា ជុច គឹមលី អ្នកត្បាញហូល «សូមកុំគិតថាតម្លៃនេះថ្លៃអី ព្រោះថាទំរាំតែត្បាញបាននូវហូល១ក្បិនៗប្រើពេលយូរ ហើយនឹងលំបាកណាស់ មើលតាំងពីបាមោកនិយាយរួមច្រើនដំណាក់កាលណាស់ ទំរាំនឹងបានវាលំបាកនឹងធ្វើ តម្លៃហូលប៉ុណ្ណោះវាមិនថ្លៃនោះទេ សូមឲ្យប្រជាជនខ្មែរយើង គាំទ្រផលិតផលខ្មែរយើងផង»៕



# របៀបជ្រើសរើសនិស្សិតរៀននៅ សកលវិទ្យាល័យការពារជាតិ

រូបភាព៖ សហការី

*ដោយ៖ ផល សុផានិត*

វិស័យការពារជាតិត្រូវគាំទ្រយ៉ាងពេញទំហឹងក្នុងបណ្តាប្រទេសជាច្រើន ព្រោះដើម្បីរក្សាសន្តិភាពជូនប្រជាជនរបស់ខ្លួន។ ចំពោះយោធិន ក៏ត្រូវតែហ្វឹកហាត់ដើម្បីទទួលបានជំនាញមួយពិតប្រាកដ។ សលកវិទ្យាល័យការពារជាតិ ត្រូវបានស្ថាបនាឡើង ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ក្នុងទិសដៅពង្រឹងស្នេរភាពជូនជាតិមាតុភូមិ។ ផល សុផានិតលំអិតរឿងនេះ៖

នៅពេលដែលនិយាយអំពីកងទ័ពនោះ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ ប្រទេសនីមួយៗ ដើម្បីរក្សាសុខ សុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋ ជាពិសេសការការពារទឹកដីពីខ្មាំងសត្រូវ។

ក្នុងការធ្វើឲ្យវិស័យមួយនេះកាន់តែរឹងមាំបន្ថែមទៀតនោះ ទាមទារឲ្យយុវជនសិក្សាឲ្យបានស៊ីជម្រៅលើផ្នែកនេះ ដើម្បីជាចំណេះដឹង ជំនាញ និងសមត្ថភាពមួយពិតប្រាកដ។

សាកលវិទ្យាល័យការពារជាតិ ត្រូវបានបង្កើតឡើងដើម្បីធ្វើការបណ្តុះបណ្តាល និស្សិតជាយោធា ឬទាហាន ដើម្បីពង្រឹងសមត្ថភាព និងកិច្ចការពារប្រទេសជាតិ ស្របតាមបទពិសោធប្រទេសទាំងឡាយនៅ លើពិភពលោក។ ជាពិសេសមហាអំណាចនានានៅលើពិភពលោកដែលចាត់ទុកសាលាមួយនេះ ជាឧស្សាហកម្មធន់ ធ្ងន់ដែលជួយបណ្តុះបណ្តាល ដឹកនាំគ្រប់គ្រង ដើម្បីសម្រេចភារកិច្ចការពារជាតិមាតុភូមិ។

សព្វថ្ងៃនេះ សកលវិទ្យាល័យការពារជាតិ មានបណ្តុះបណ្តាលថ្នាក់ បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតផ្នែកវិទ្យាសាស្ត្រយោធា និងវិទ្យាសាស្ត្រសង្គម ដល់កងយោធពលខេមភូមិន្ទ។ ក្នុងនោះមាន៥មហាវិទ្យាល័យ គឺមហាវិទ្យាល័យការពារជាតិ មហាវិទ្យាល័យបញ្ជាការសេនាធិការ មហាវិទ្យាល័យសង្គមនិងភាសា មហាវិទ្យាល័យស្រាវជ្រាវចិត្តសាស្ត្រយោធា និងមហាវិទ្យាល័យព័ត៌មានវិទ្យា ភស្តុភានិងហិរញ្ញវត្ថុ។ ក្រោយបញ្ចប់ការសិក្សា និស្សិតអាចទទួលបានតួនាទីផ្សេងៗគ្នាទៅតាមសមត្ថភាព។

សាលាជាតិយោធាមួយនេះ មានសាស្ត្រាចារ្យចាប់ពីថ្នាក់ឧត្តមសិក្សារហូតដល់បណ្ឌិត។ តាមស្មារតីចំពោះមុខ យោធាកម្ពុជា ចាំបាច់ត្រូវទទួលការបណ្តុះបណ្តាលធនធានមនុស្សរបស់ខ្លួនលើគ្រប់កម្រិត គ្រប់ជំនាញ ដូចជា វិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រយោធា។

ឧត្តមសេនីយ៍ត្រី រស់ សុគន្ធ នាយករងមហាវិទ្យាល័យបញ្ជាការសេនាធិការ៖ «សិក្ខាកាមនិស្សិតរបស់យើងទទួល ការស្នាក់នៅ នៅទីនេះ ទទួលការហូបចុកទៅតាមគោលរបបរបស់ក្រសួងការពារជាតិ។ និស្សិតស្នាក់នៅទីនេះ ខុសប្លែកពីសកលវិទ្យាល័យផ្សេងៗ ចំពោះយោធារបស់យើងមិនមានផ្ទះស្នាក់នៅ ក្នុងភ្នំពេញទេ សាលាកំណត់ថា ត្រូវឲ្យនិស្សិតស្នាក់នៅទីនេះ ការស្នាក់នៅទីនេះងាយស្រួលក្នុងការគ្រប់គ្រងផង ការហូបចុកជារួម»។

ការសិក្សានៅក្នុងសាលានេះ ជាការលត់ដំខ្លួនជាខ្លាំង តាមរយៈការហ្វឹកហ្វឺនក្នុងវគ្គនីមួយៗ ដើម្បីទទួលបានបទពិសោធសម្រាប់និស្សិត និងដើម្បីធ្វើឲ្យមានគុណភាព តម្រូវការរបស់កងយោធពលខេមរភូមិន្ទ។



រូបភាព៖ សហការី

ឧត្តមសេនីយ៍ត្រីរស់ សុគន្ធ៖ «ការសិក្សានៅទីនេះ ខុសប្លែកពីសកលវិទ្យាល័យផ្សេងៗទៀត ព្រោះថានៅទីនេះ ជាសកលវិទ្យាល័យយោធា ក្រៅពីការរៀនយោធា ក៏សកលនេះតម្រូវឲ្យមានការសិក្សាខាងវិទ្យាសាស្ត្រសង្គមដែរ ដូចជាភាពជាអ្នកដឹកនាំ នយោបាយសាធារណៈ ឬក៏មេរៀនផ្សេងៗទៀតទាក់ទងនិងច្បាប់ ដែលប្រទេសជាតិយើងត្រូវការ ចំពោះការសិក្សាយោធា ក្រៅពីការសិក្សានៅក្នុងថ្នាក់ យើងឲ្យសិស្សប្រើខួរក្បាលកាយសម្បទា អ្នកសិក្សានៅទីនេះ សិក្សាក្នុងនាមជាមេបញ្ជាការ មិនមែនជានាយទាហានទេ ជាអ្នកតាក់តែងប្រយុទ្ធ របៀបត្រៀមការពារ» ។

ការសិក្សាផ្នែកយោធានេះ តម្រូវឲ្យនិស្សិតមានចំណេះដឹងទូលំទូលាយ អត់ធ្មត់ និងមានកាយសម្បទារឹងមាំ ដើម្បីហ្វឹកហាត់ជាមួយនឹងអាវុធផ្សេងៗ។ យ៉ាងណាក៏ដោយនិស្សិតទាំងឡាយ មុននឹងចូលរៀននៅសាលាយោធានេះ បេក្ខជនត្រូវដាក់ពាក្យប្រឡង លើមុខវិជ្ជាចំណេះដឹងទូទៅ(ថ្នាក់ទី១២) និងវិញ្ញាសារកាយសម្បទា ( កីឡា ) និងភាសាបរទេសមានអង់គ្លេស ឬបារាំង។

ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ បានថ្លែងនៅក្នុងការប្រឡងជ្រើសរើសសិក្ខាកាមយោធាឆ្នាំ២០១៩ កាលពីពេលថ្មីៗនេះថា ការប្រឡងជ្រើសរើសនាយទាហាននឹងប្រព្រឹត្តទៅដោយរលូន ត្រឹមត្រូវ មានតម្លាភាព និងយុត្តិធម៌ហើយថា អ្នកដែលបានជោគជ័យ និងត្រូវបានជ្រើសរើសយកធ្វើជាទាហាន គឺដោយសារតែសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ ដោយមិនអាចមានការជួយអន្តរាគមន៍ណាមួយឡើយ។

លោកបញ្ជាក់ថា៖ «ការប្រកួតប្រជែង និងការខិតខំរបស់ប្អូនៗ សម្រាប់ការប្រឡងលើកនេះសូមយកចិត្តទុកដាក់ឲ្យមែនទែន ហើយភារកិច្ចរបស់អនុគណៈកម្មការប្រឡង ក៏ដូចជាគណៈកម្មការជ្រើសរើសរបស់យើងគឺថា ធ្វើម៉េចឲ្យការប្រឡង ការជ្រើសរើស នាយទាហានរបស់យើង ប្រព្រឹត្តទៅដោយរលូន ត្រឹមត្រូវមានតម្លាភាពនិងយុត្តិធម៌»។

លោកបន្ថែមថា បេក្ខជនទាំងអស់ ត្រូវហ៊ានទទួលខុសត្រូវនិងត្រូវហ៊ានប្រកួត ដោយតម្លាភាព និងយុត្តិធម៌ ហើយបានព្រមានថា ពួកគេមិនត្រូវធ្វើសកម្មភាពណាមួយដែលរំលោភលើបទបញ្ជាផ្ទៃក្នុង ដើម្បីទទួលបានជោគជ័យឡើយ។ លោកក៏បានណែនាំអនុគណៈកម្មការប្រឡងជ្រើសរើស ក៏ដូចជាគណៈមេប្រយោគ អគានុរក្ស និងអនុរក្សត្រូវអនុវត្តបទបញ្ជាឲ្យបានម៉ឺងម៉ាត់នៅក្នុងដំណើរការនៃការប្រឡងនេះ។

នៅក្នុងឆ្នាំ១៩៩៥ សកលវិទ្យាល័យការពារជាតិ គ្រាន់តែជាសាលាភាសាអង់គ្លេស សម្រាប់កងទ័ព ក្នុងការហ្វឹកហ្វឺនភាសាអង់គ្លេស។ នៅក្នុងឆ្នាំ១៩៩៦ ការប្រើប្រាស់ភាសានៅក្នុងប្រទេសកាន់តែទូលាយ ក្រសួងការពារជាតិ បានប្តូរសាលាមួយនេះទៅជាមជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាបរទេស ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ អន្តរជាតិ ក្រោយ មកដោយសារតែការវិវត្តន៍របស់កម្ពុជា រដ្ឋាភិបាលប្តូរឈ្មោះសាលានេះទៅជាសកលវិទ្យាល័យការពារជាតិវិញ៕

# វិស័យ សូត្រខ្មែរ នៅកម្ពុជា

*ដោយ៖ ផល សុផានិត*

ដង្កូវនាងគឺជាសត្វល្អិតមួយប្រភេទ ដែលមានសំណាងជាង សត្វល្អិតដទៃទៀត ព្រោះវាត្រូវបានមនុស្សមើលថែយ៉ាងល្អបំផុត ដើម្បីទទួលបាននូវសរសៃសូត្រមាស។ ដង្កូវនាង ឬពាក្យសាមញ្ញដែលពលរដ្ឋថា នាង ត្រូវបានចិញ្ចឹម នៅរមណីយដ្ឋានកែច្នៃមួយនៅជាយក្រុងភ្នំពេញ ឈ្មោះថា ចម្ការស្នេហ៍ ស្ថិតក្នុងឃុំកោះឧញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

ការចិញ្ចឹមកូននាង ដើម្បីទទួលបានសរសៃសូត្រ ត្រូវរង់ចាំការវិវត្តជាច្រើនដំណាក់កាល។

ម្ចាស់ហាងចម្ការស្នេហ៍ លោក ពេជ្រ វ៉ាង បានប្រាប់ពីវិធីសាស្ត្រនៃដំណាក់កាលនីមួយៗថា៖ «ដំបូងត្រូវយកមេអំបៅនាង ទាំងញីនិងឈ្មោល ដាក់នៅលើក្រដាសកាសែត រយៈពេល៨ម៉ោង ដើម្បីទទួលបានពង និងធ្វើការផ្តាច់មេអំបៅទាំងពីរចេញពីគ្នា ហើយទុកមេអំបៅញី នៅលើក្រដាសដើម្បីពង ដែលក្នុងមួយមេ អាចពងកូនបាន ១០០ពងកូន»។

ស្លឹកមន គឺជាអាហារតែមួយមុខគត់របស់នាង។ ពួកវាចាប់ផ្តើមស៊ីស្លឹកមន តាំងពីនៅតូចៗមកម្ល៉េះ។ នៅពេលនាងនៅតូចគេហាន់ស្លឹកមនជាសរសៃតូចៗ ដើម្បីឲ្យកូននាងងាយស្រួលស៊ី។ ក្នុងមួយថ្ងៃកូននាងស៊ីស្លឹកមនពី៣ទៅ៤ដង និងត្រូវថែទាំដោយយកចិត្តទុកដាក់បំផុត។ គេចិញ្ចឹមនាងរបៀបនេះ រហូតដល់នាងអាយុ ១ខែ៨ថ្ងៃ កូននាងចាប់ផ្តើមផ្លាស់ប្តូរពណ៌សម្បុរពីសទៅលឿង។

លោក ពេជ្រ វ៉ាងបានឲ្យដឹងថា៖ «ដង្កូវនាងនេះ គេចាប់ផ្តើមប្តូរពណ៌ពីសទៅលឿង ដើម្បីបញ្ជាក់ថាក្នុងខ្លួននាង មានសូត្រ។ ដូច្នេះគេត្រូវការកន្លែងមួយទៀត ហើយយើងចាប់ផ្តើមចាប់កូននាង មកដាក់ក្នុងសំបុកធ្វើពីឈើ ឬជ័រ។ តែជាធម្មតាគេប្រើឈើទើបល្អ»។

នៅពេលដែលកូននាងនៅលើសំបុក កូននាងមិនត្រូវការអាហារទៀតទេ ដែលជាតំណាក់កាលដែលនាងបញ្ចេញសរសៃសូត្រមាសចេញពីមាត់ ដើម្បីរុំព័ទ្ធខ្លួនរបស់វា។ ការខ្ជាក់សរសៃសូត្រត្រូវការរយៈពេល២៤ម៉ោង។

លោក ពេជ្រ វ៉ាង៖ «ចាប់ពីល្ងាចរហូតដល់ព្រឹក កូននាងនីមួយៗគេធ្វើបានសំបុកនាង។ នៅពេលដែលគេចាប់ផ្តើមធ្វើ គេចាប់ផ្តើមរុំខ្លួនគេរហូតដល់អស់ជាតិសូត្រ ដែលវិវត្តទៅរកឌុកឌឿ។ យើងទុក២០%ដើម្បីធ្វើពូជ និង ៨០% យើងធ្វើសូត្រ។ ក្នុង២០% យើងទុកគេនៅក្នុងសំបុក មិនចាំបាច់យកចេញក្រៅនោះទេ ហើយ៨០%នៃសំបុកនាងនេះ យើងធ្វើសូត្រ»។



ការត្បាញសូត្ររបស់ប្រជាជនក្នុងក្នុងឃុំកោះឧញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ រូបភាព៖ សហការី



កូនដង្កូវនាងស៊ីស្លឹកមន។ រូបភាព៖ ស៊ីអេសស៊ី



ដង្កូវនាងប្រែពណ៌នៅក្នុងសំបុក។ រូបភាព៖ ស៊ីអេសស៊ី

លោក ពេជ្រ វ៉ាង បន្តថា មុននឹងធ្វើសូត្រ យើងឲ្យកូននាងស្លាប់នៅក្នុងសំបុកសិន។ បើសិនយើងមិនធ្វើឲ្យស្លាប់ទេ គឺមេអំបៅក្នុងសំបុកនិងកើតចេញក្រៅ ធ្វើឲ្យសរសៃសូត្របាក់ ដែលមិនអាចប្រើប្រាស់បានទេ។

លោក ពេជ្រ វ៉ាង «របៀបនៃការសម្លាប់គឺគ្រាន់តែដាក់ហាលថ្ងៃ តែតំបន់ខ្លះក៏គេថែរក្សាឌុកឌឿនេះ ឲ្យនៅថ្លោសដដែល គេយកទៅដាក់ក្នុងទឹកក្តៅតែម្តង មុនពេលគេកាត់ចេញ ព្រោះចង់រក្សាឌុកឌឿឲ្យថ្លោស តែបើហាលថ្ងៃមេអំបៅតូច ស្ងួត នោះយើងញាំមិនកើតទេ»។

ក្នុងសំបុកនាងមួយ គេអាចស្រាវយកបានសរសៃចំនួនពី៧០០ ទៅ១០០០ម៉ែត្រ។ ក្នុងការស្រាវ គេយកសំបុកនាងដែលដាក់ហាលថ្ងៃ រួចដាក់ក្នុងទឹកពុះ ១០០អង្សា រួចក៏ចាប់ផ្តើមស្រាវ វិញជាខ្សែក្នុងខារ។

សរសៃសូត្រមាស ដែលទាញយកចេញពីសំបុកនាងមាន២ប្រភេទ។ ប្រភេទទី១មានពណ៌ស រាងគ្រើម ស្ថិតនៅស្រទាប់ក្រៅនៃសំបុកនាង ចំណែកផ្នែកខាងក្នុងមានពណ៌មាស រាងទន់ហើយម៉ត់ល្អ។

មុនពេលយកទៅត្បាញ គេត្រូវយកសរសៃសូត្រទៅជ្រលក់ពណ៌ តាមតម្រូវការ។ បន្ទាប់មកគេយកវាទៅ ប្រមោកនឹងទឹកក្បុង ដើម្បីឲ្យសូត្រទន់ល្អ និងមិនជំពាក់។ គេយកខ្នារសរសៃសូត្រ ដែលខាររួចទៅបញ្ចូលក្នុងកីត្បាញ ដើម្បីត្បាញជាក្រមាសូត្រ សំពត់សូត្រ ហូល ឬផាមួង តាមតម្រូវការ។

កាលពីពេលថ្មីៗនេះ មជ្ឈមណ្ឌលសូត្រខ្មែរ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ឯកឧត្តមរដ្ឋមន្ត្រី ហង់ជួនណារ៉ុន មានប្រសាសន៍ថា ការដាំមន ចិញ្ចឹមដង្កូវនាង មានតាំងពីយូរណាស់មកហើយ នៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែបច្ចុប្បន្នដោយសារកត្តាមួយចំនួន ដែលធ្វើឱ្យវិស័យនេះមិនសូវមានការរីកចម្រើន ជាពិសេសគឺខ្វះខាតនូវការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍបែបវិទ្យាសាស្ត្រ។

ឯកឧត្តមរដ្ឋមន្ត្រី បានបញ្ជាក់ផងដែរថា វិស័យសូត្រនេះ មានសារៈសំខាន់ខ្លាំងណាស់ និងផ្តល់ប្រយោជន៍ជាច្រើន ចំពោះប្រជាកសិករដូចជា៖ ទី១. ផ្តល់ការងារ និងប្រាក់ចំណូលបន្ថែមដល់កសិករ, ទី២. ផ្តល់លទ្ធភាពឱ្យចាស់ជរា ស្ត្រី និងជនពិការអាចចូលរួមបាន, ទី៣. កាត់បន្ថយចំណាកស្រុក, ទី៤. មិនប៉ះពាល់ដល់បរិស្ថាន និងទី៥. អភិរក្សនិងលើកស្ទួយប្រពៃណីទំនៀមទំលាប់ខ្មែរយើង។

សារៈសំខាន់បន្ថែមទៀតនោះ គឺចង់ឲ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផលិតពងដង្កូវនាង ដែលគ្មានជំងឺ ហើយផ្គត់ផ្គង់ទៅដល់កសិករប្រមាណ ៥០គ្រួសារ ព្រមទាំងផ្ទេរបច្ចេកទេសទៅដល់កសិករទាំងនេះ ដើម្បីឱ្យពួកគាត់អាចចិញ្ចឹមដង្កូវនាងប្រកបដោយស្ថេរភាព និង អាចបង្កើនប្រាក់ចំណូលទាំងកសិករ និងភាគីពាក់ព័ន្ធនៃឧស្សាហកម្មសូត្រ៕



រោងសិប្បកម្មចម្លាក់ឈើ អង្គរជុំ។ រូបភាព៖ សហការី

# សិប្បកម្មចម្លាក់ឈើផ្ដល់ចំណូល ប្រសើរ និងផ្ដល់ការងារដល់ប្រជាជន



ចម្លាក់រូបប្រាសាទអង្គរនៅលើផ្តិលធ្វើពីឈើ។
រូបភាព៖ សហការី

ចម្លាក់ខ្មែរកើតឡើងតាំងពីយូរលង់មកហើយ ដោយមានទាំងចម្លាក់លិប ចម្លាក់លៀន និងចម្លាក់លោត។ យើងអាចមើលឃើញបាននៅតាមប្រវត្តិសាស្ត្ររបស់ខ្មែរ និងទឹកដៃដែលបន្សល់ទុកនៅតាមប្រសាទនានា ដែលបញ្ជាក់ថា ខ្មែរយើងមានជំនាញសិល្បៈនិងអរិយធម៌ដ៏អស្ចារ្យមួយក្នុងចំណោមបណ្ដាប្រទេសដទៃទៀត។

នាពេលបច្ចុប្បន្ន ប្រជាជននិយមប្រើប្រាស់ឈើ ជាគ្រឿងសង្ហារឹម និងគ្រឿងតុបតែងផ្ទះ ហើយគ្រឿងទាំងនោះភាគច្រើនត្រូវបានឆ្លាក់ជាក្បាច់ក្បូរផ្សេង ៗតាមបែបបុរាណខ្មែរ។ ជាមួយការពេញនិយមនេះ សិប្បកម្មចម្លាក់ឈើ មួយកន្លែងរកចំណូលនិងផ្ដល់ការងារឲ្យប្រជាជនយ៉ាងគាប់ចិត្តផងដែរ។

*ដោយ៖ ផល សុផានិត*

ចម្លាក់ឈើជាទីពេញនិយមរបស់ប្រជាពលរដ្ឋខ្មែរ សម្រាប់ដាក់តាំងនៅតាមគេហដ្ឋាន ហាងអាជីវកម្ម និងសណ្ឋាគារនានា។ ម្ចាស់សិប្បកម្មចម្លាក់ឈើអង្គរជុំ ដែលមានទីតាំងនៅសង្កាត់ផ្សារក្រោម ក្រុងសៀមរាប ខេត្តសៀមរាប បានដំណើរការជិត ២០ឆ្នាំមកហើយ។ លោកបានឲ្យដឹងថា ហាងរបស់លោកទទួលឆ្លាក់ឈើជាផ្ទាំងធំៗ ដែលមានរូបរាងជាក្បាច់រចនាផ្សេងៗតាមបែបសិល្បៈខ្មែរ។ ចម្លាក់ស្ទើរតែទាំងអស់របស់សិប្បកម្មមួយនេះ គឺជាចម្លាក់លៀន។

លោក ហួរ ហាញ់ ម្ចាស់សិប្បកម្មចម្លាក់ឈើ អង្គរជុំ បានថ្លែងឲ្យដឹងថា៖ «មកដល់នឹងពេលនេះ ការរីកចម្រើនការងារ ទាំងអតិថិជនដែលគាត់បញ្ជាទិញភាគច្រើនគាត់ដាក់តាមផ្ទះ ដាក់ផ្ទះវីឡា ដាក់អូតែល ភាគច្រើននៅតាមភូមិគ្រឹះ។ សព្វថ្ងៃចម្លាក់ដែលដាច់ជាងគេគឺរូបអង្គរវត្ត ដឹកស្មៀង និងសវនាការ»។



ក្នុងមួយខែៗ សិប្បកម្មរបស់លោកបានបញ្ចេញផ្ទាំងចម្លាក់ទៅឲ្យអតិថិជនចន្លោះពី ៣ទៅ៥ផ្ទាំង និងមានតម្លៃចន្លោះពី ២៥០០ ទៅ៣៥០០ ដុល្លាអាមេរិក។ លោកបានឲ្យដឹងទៀតថា អតិថិជន បានដឹកយកមកឲ្យភាគច្រើនគឺឈើ គគី និងកកោះ ដែលមានទំហំមុខកាត់ ១ម៉ែត្រ និងបណ្ដោយ៣ម៉ែត្រ។

លោកបញ្ជាក់ថា ការឆ្លាក់មានរយៈពេលខ្លីជាងពេលមុន បើធៀបទៅនឹងរបៀបរបបពីបុរាណ ដោយសារមានឧបករណ៍និងម៉ាស៊ីនម៉ូទ័រទំនើបៗ។ ហើយដើម្បីប្រែក្លាយកំណាត់ឈើទៅជាផ្ទាំងឈើដ៏ស្រស់ស្អាតនោះ លោក ហួរ ហាញ់ ត្រូវប្រើកម្លាំងជាងចំនួន ៥នាក់ និងចំណាយពេល១ខែក្នុងឈើមួយផ្ទាំង។ រីឯការលើកដាក់ផ្ទាំងឈើធំៗត្រូវការកម្លាំងពលកម្មច្រើន។

លោក ហួរ ហាញ់៖ «ឥលូវមានភាពងាយស្រួល ត្រង់ថាបច្ចុប្បន្ននេះមានម៉ាស៊ីនជួយជាជំនួយ មិនដូចកាលពីពេលមុននោះទេ ជាងត្រូវប្រើដៃក្នុងការឆ្លាក់ តែបច្ចុប្បន្ននេះទោះបីជាយើងប្រើម៉ាស៊ីន តែផ្នែកខ្លះក៏យើងត្រូវប្រើដៃដើម្បីឆ្លាក់វាដែរ»។

លោក ហួរ ហាញ់ បានសិក្សាជំនាញឆ្លាក់ឈើនេះរយៈពេល៦ឆ្នាំ តាំងពីឆ្នាំ១៩៩៣ ក្នុងវ័យ១៦ឆ្នាំ នៅសាលាវិចិត្រសិល្បៈខេត្តសៀមរាប និងបានចេញឆ្លាក់នៅតាមក្រុមហ៊ុននានា មុននឹងលោកបង្កើតសិប្បកម្មផ្ទាល់ខ្លួន។ លោកមានប្រសាសន៍រំលឹកថា អ្វីដែរលំបាកជាងគេ គឺដំបូងគាត់ត្រូវសុំការងារពីអតិថិជន ពេលខ្លះក៏បាន ពេលខ្លះក៏មិនបាន។ ប៉ុន្តែដោយសារតែស្នាដៃរបស់គាត់មានទឹកដៃល្អ ទើបធ្វើឲ្យអតិថិជនចាប់ផ្ដើមទទួលស្គាល់ និងគាំទ្រសិប្បកម្មចម្លាក់ឈើអង្គរជុំកាន់តែច្រើនឡើងៗ។ ម្ចាស់អាជីវកម្មរូបនេះ ឲ្យដឹងថា គាត់ចាប់ផ្ដើមដោយមានរោងតូចមួយជាមួយជាងចម្លាក់៥នាក់ ប៉ុន្តែបច្ចុប្បន្នគឺមានជាងចំនួន២០នាក់។

លោកហួរ ហាញ់ បន្ថែមថា ទោះយ៉ាងណា សិប្បកម្មចម្លាក់នេះក៏ប្រឈមនូវបញ្ហាបន្តិចបន្តួចដែរ ព្រោះបើធ្វើប្រហែសផ្នែកណាមួយនៃឈើនោះនឹងធ្វើឲ្យពិបាក ដូច្នេះត្រូវទាមទារអ្នកជំនាញធ្វើការ។ ប្រសិនបើខូចខាតតិចតួច យើងអាចជួលជុលបានដោយប្រើការបិត។

អ្នកនាង ចាន់ សឿន ជាសិប្បិនីចម្លាក់ឈើ មានវ័យ២៨ឆ្នាំ បានឲ្យដឹងថា អ្នកនាងបានចាប់អាជីព ជាជាងចម្លាក់ អស់រយៈពេលជាង ១២ឆ្នាំមកហើយ។ អ្នកនាងបន្ថែមថា ការប្រកបរបរជាជាងចម្លាក់ បានធ្វើឲ្យចំណូលរបស់នាងទៀងទាត់ និងធ្វើឲ្យជីវភាពរបស់អ្នកនាងប្រសើរជាងមុន។

ថ្វីបើគ្មានកម្លាំងខ្លាំងអាចធ្វើការងារដូចជាបុរស ប៉ុន្តែក្រុមជាងរបស់អ្នកនាង ដែលមានភាគច្រើនជានារី (ក្រុមជាងដែរជានារីៗ ត្រូវការប្រើដៃដើម្បីឆ្លាក់ក្បាច់ល្អិតៗ) មានជំនាញខ្ពស់ខាងចម្លាក់ក្បាច់តាមប្រាសាទនានា។

អ្នកនាងចាន់ សឿន៖ «និយាយរួមខាងក្បាច់ គឺខាងស្រីៗ។ និយាយរួមក្បាច់វាមានការលំអិតច្រើនជាងរូប ដែលវាមានក្បាច់ច្រើន និយាយរួមគឺយើងអាចឆ្លាក់បានទាំងអស់»។

បច្ចុប្បន្នទីផ្សារចម្លាក់ឈើ នៅមានប្រជាប្រិយភាពនៅក្នុងសង្គមខ្មែរ សម្រាប់ការដាក់តាំងលំអរនៅក្នុងគេហដ្ឋាន និងតាមទីតាំងសំខាន់ៗនានា តែបញ្ហាដែរចោទសំខាន់នោះគឺធនធានជំនាញចម្លាក់ឈើនៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ។ ម្ចាស់សិប្បកម្មខាងលើ បានបញ្ជាក់ថា ការចាប់យកជំនាញចម្លាក់ឈើអាចរកប្រាក់ចំណូលបានគួរសម និងល្អជាងចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស៕

# អំពើហិង្សាលើកុមារនៅតែមាន ប៉ុន្តែកម្ពុជាប្តេជ្ញានឹងបញ្ចប់វា

*ដោយ៖ អរិយបុត្រ*



អំពើហិង្សាគ្រប់រូបភាពលើកុមារប្រហែលជានៅមិនទាន់អាចលុបបំបាត់អស់ពីប្រទេសកម្ពុជានៅឡើយទេ ប៉ុន្តែប្រទេសកម្ពុជាប្តេជ្ញាបញ្ចប់អំពើហិង្សាលើកុមារ។

នៅក្នុងខណៈពេលដែលអាជ្ញាធរ និងមន្ត្រីជំនាញបរទេសកំពុងតែធ្វើកិច្ចការឆ្ពោះទៅរកការបញ្ចប់អំពើហិង្សានៅលើកុមារនេះ ប្រជាពលរដ្ឋមួយចំនួនបានបញ្ចេញទស្សនៈថា ប្រហែលត្រូវការពេលវេលា និង ការប្តេជ្ញាចិត្តខ្ពស់ណាស់ ប្រសិនបើទាំងអស់គ្នាចង់កុំឲ្យមានអំពើហិង្សានៅលើកុមារ ។

លោករិន ពិសី ដែលជាប្រជាពលរដ្ឋដែលមានវ័យ ៣៨ឆ្នាំ និង សព្វថ្ងៃជាអាណាព្យាបាលគ្រួសារមួយ ដែលមានកូន ២នាក់នៅក្នុងបន្ទុក បានអះអាងថា វាគឺជារឿងល្អ ដែលកុមារមិនមានអំពើហិង្សា ហើយលោកគាំទ្រពេញទំហឹង បើទោះបីជាពេលនេះរូបលោក និងគ្រួសារ (ភរិយា) ពេលខ្លះនៅតែប្រើប្រាស់អំពើហិង្សាដាក់កូននៅឡើយក៏ដោយ។

លោកបានបញ្ជាក់ថា៖ «រឿងវាយប្រដៅកូនអីនេះ គ្មាននរណាចង់ទេបង (អ្នកយកព័ត៌មាន) ប៉ុន្តែវាចេះតែអត់មិនបាន»។ លោកបានបន្តទៀតថា តាំងពីដើមមកដល់ឥឡូវ លោកពិតជាពិបាកជឿណាស់ដែលមានគ្រួសារមិនដែលវាយកូនសោះនោះ។

លោកស្រី ជាង សុផានី ជាស្ត្រីមេផ្ទះ មួយរូប បានចូលរួមបញ្ចេញយោបល់ថា អារឿងវាយប្រដៅកូនបន្តិចបន្តួចនៅក្នុងគ្រួសារប្រហែលជាមិនមែនជារឿងអំពើហិង្សាទេ កុំឲ្យតែយើងទៅវាយកូននឹងខ្សែរ ភ្លើង ចង អីបានវាអាក្រក់មិនគួរឲ្យមានមែន។

លោកស្រីបានបញ្ជាក់ថា៖ «អារឿងអំពើហិង្សាតិចតួច គឺខ្ញុំមិនអាចនិយាយថា អត់បានទេ ព្រោះវាក្នុងគ្រួសារ។ ទាំងគេទាំងខ្ញុំ ជួនកាលអត់មិនបានដែរ ចឹងហើយបានខ្ញុំជឿថា គ្មានគ្រួសារណាមិនវាយសោះនោះទេ»។

បុគ្គលិកផ្នែកអប់រំកុមារមួយរូបដែលសុំមិនបញ្ចេញអត្តសញ្ញាណបានឲ្យដឹងថា នោះជារឿងពិត។ ប្រជាពលរដ្ឋ ភាគច្រើននៅកម្ពុជាមិនចាត់ទុក រឿងវាយប្រដៅកូននេះថា ជារឿងអំពើហិង្សានោះទេ ប៉ុន្តែទោះបីជាយ៉ាងណាវាគឺជាទម្រង់មួយនៃអំពើហិង្សា។

លោកស្រីបានបញ្ជាក់ថា៖ «ខ្ញុំជឿថា គ្មាននរណាគិតថា ការវាយប្រដៅកូនជាអំពើហិង្សានោះទេ នៅក្នុងសង្គមខ្មែរ ដោយសារតែកើតប្រេចមក គឺឃើញតែបែបនេះ ប៉ុន្តែសូមកុំភ្លេចថា នេះជាទម្រង់មួយនៃអំពើហិង្សា គ្រាន់តែវាជាករណីស្រាល»។

លោកស្រី បានឲ្យដឹងទៀតថា៖ «ដូច្នេះអាណាព្យាបាលនានាគួរតែរៀនកាត់បន្ថយ នឹងព្យាយាមកុំឲ្យមាន។ នោះគឺជាទម្លាប់ ហើយបើយើងព្យាយាមអត់បាន នោះវានឹងលែងមាន»។

ទាក់ទិននឹងរឿងអំពើហិង្សាលើកុមារនេះ កាលពីពេលថ្មីៗនេះ ប្រទេសកម្ពុជាត្រូវបានគេប្រកាសថា កម្ពុជាបានក្លាយជាសមាជិកទី២៦នៃប្រទេសជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងជាប្រទេសឈានមុខនៅក្នុងតំបន់ ដែលបានបង្ហាញពីការប្តេជ្ញាចិត្តក្នុងការបញ្ចប់អំពើហិង្សាគ្រប់រូបភាពលើកុមារ។

ក្រសួងសង្គមកិច្ច និង អង្គការយូនីសេហ្វ បានអះអាងថា ប្រទេសកម្ពុជាគឺជាប្រទេសទី៤នៅក្នុងតំបន់ ដែលបានក្លាយជាប្រទេសនាំមុខបន្ទាប់ពីប្រទេសឥណ្ឌូណេស៊ីប្រទេសហ្វីលីពីន និងប្រទេសម៉ុងហ្គោលី។ការប្តេជ្ញាចិត្តនេះធ្វើឡើងខណៈដែលកម្ពុជាកំពុងពន្លឿនកិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចចក្ខុវិស័យ ប្រែក្លាយពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

តាមការសិក្សាអង្កេតថ្នាក់ជាតិស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាក្នុងឆ្នាំ២០១៣ បានបង្ហាញថាក្នុងចំណោមកុមារចំនួន២នាក់ មានម្នាក់បានទទួលរងយ៉ាងហោចណាស់មួយទម្រង់នៃអំពើហិង្សា មុនពេលពួកគេឈានដល់វ័យ១៨ឆ្នាំ។ អំពើហិង្សាលើកុមារ គឺជាបញ្ហាសកលដែលបង្កផលវិបាកធ្ងន់ធ្ងរស្ទើរពេញមួយជីវិតដល់សង្គមជាតិ។ អំពើហិង្សាលើកុមារបានធ្វើឱ្យកុមារ និងគ្រួសារទទួលរងនូវការឈឺចាប់ និងអាចបង្កផលវិបាករយៈពេលវែងដូចជា ការអភិវឌ្ឍរូបរាងកាយយឺត បញ្ហាឥរិយាបថ បញ្ហាសុខភាពផ្លូវកាយ និងបញ្ហាសុខភាពផ្លូវចិត្តជាដើម។

លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានមានប្រសាសន៍ថា៖ «ក្នុងទិសដៅឆ្លើយតបនឹងបញ្ហាអំពើហិង្សាលើកុមារ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ចំពោះការលើកកម្ពស់អនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់អន្តរជាតិពាក់ព័ន្ធនានា ឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ និងកិច្ចការពារជាពិសេសសម្រាប់កុមារ ដើម្បីអាចឱ្យកុមាររស់នៅក្នុងសេរីភាព សន្តិភាព និងការអភិវឌ្ឍ តាមរយៈការដាក់ចេញនូវវិធានការជាច្រើនរួមមាន ការរៀបចំច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានាជាច្រើនដើម្បីធានាដល់កិច្ចការពារកុមារឱ្យកាន់តែប្រសើរឡើង»។

លោកស្រី គ្រីស្ស៊ៀន ម៉ុនឌ័រតេ នាយិកាយូនីសេហ្វប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា៖ «កិច្ចការពារកុមារពីអំពើហិង្សាគ្រប់រូបភាព ត្រូវបានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ព្រឹត្តិការណ៍នៅថ្ងៃនេះ គឺជាជំហានដ៏មានសារៈសំខាន់ ដើម្បីឆ្ពោះទៅសម្រេចសិទ្ធិរបស់កុមារកម្ពុជាគ្រប់រូប ដើម្បីឱ្យពួកគេអាចធំដឹងក្តីប្រកបដោយសុវត្ថិភាព និងទទួលបានការការពារ។ គ្មានហេតុផលណាមួយនាំឱ្យពួកគេត្រូវប្រព្រឹត្តអំពើហិង្សាលើកុមារឡើយ ហើយអំពើហិង្សាលើកុមារគឺជាទង្វើដែលមិនត្រូវអត់ឱនឲ្យជាដាច់ខាត។ ការបញ្ចប់អំពើហិង្សាលើកុមារ គឺជាសកម្មភាពដែលអាចធ្វើទៅបាន ហើយការបញ្ចប់អំពើហិង្សាលើកុមារគឺជាការទទួលខុសត្រូវរួមរបស់យើង»។

លោក ហូវើដ ថាយល័រ នាយកប្រតិបត្តិនៃភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ បានមានប្រសាសន៍ថា៖ «យើងបានចាប់ផ្តើមភាពជាដៃគូថ្មីជាមួយរាជរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន រួមទាំងក្រុមការងារ និងបុគ្គលសំខាន់ៗនៅក្នុងប្រទេសកម្ពុជា។ យើងរួមគ្នាក្នុងគោលដៅតែមួយ គឺយើងចង់បានសង្គមមួយដែលកុមារគ្រប់រូបចម្រើនពេញវ័យប្រកបដោយសុវត្ថិភាព និងសន្តិសុខ។ កិច្ចខិតខំប្រឹងប្រែងរបស់យើង គឺជាការវិនិយោគដ៏ឆ្លាតវៃទៅលើកុមារគ្រប់រូបនៅថ្ងៃនេះ ហើយវានឹងផ្តល់ត្រឡប់មកវិញនូវលទ្ធផលវិជ្ជមានជាច្រើនជំនាន់ទៅខាងមុខ»។

ការសម្រេចចិត្តរបស់កម្ពុជា ក្នុងប្រទេសភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ត្រូវបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅ។ ពិធីប្រកាសជាផ្លូវការនាថ្ងៃនេះ មានអ្នកចូលរួមប្រមាណ៣០០នាក់ មកពីតំណាងអង្គទូត ក្រសួង ស្ថាប័ន រាជធានី ខេត្ត សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ អ្នកជំនាញវិស័យឯកជន និងអ្នកសារព័ត៌មាន៕

# ការកែច្នៃ សំណល់ ឱ្យទៅជាវត្ថុថ្មី





*កូនសិស្សរបស់អង្គការវិចិត្រករខ្មែរដើម្បីកុមារ កំពុងរៀនឆ្លាក់ទៀនចេញជារបស់សិល្បៈផ្សេងៗ។ រូបភាព៖ អង្គការវិចិត្រករខ្មែរដើម្បីកុមារ*

**បើនិយាយទៀនសម្រាប់ដុតបំភ្លឺនៅពេលរាត្រីនោះ គេហាក់សឹងតែស្គាល់និងយល់គ្រប់គ្នានូវឈ្មោះសាមញ្ញរបស់វត្ថុមួយនេះ។ ក្នុងខែនេះសឹងតែគ្រប់វត្តអារាមនៅក្នុងប្រទេសកម្ពុជាតែងតែដុតទៀនបំភ្លឺជារៀងរាល់ពេល សំណល់ដលកើតចេញពីទឹកទៀនស្រក់ត្រូវបានវិចិត្រករខ្មែរមួយរូបប្រមូលយកទៅកែច្នៃឡើងវិញ។**

ទៀនត្រូវបានប្រជាពលរដ្ឋខ្មែរប្រើប្រាស់ធ្វើជាគ្រឿងសក្ការបូជា បំភ្លឺ សឹងតែគ្រប់រដូវកាល គ្រប់ទីកន្លែងមិនថាជនបទឬទីក្រុងនោះទេ។ សំណល់ដែលកើតចេញពីទឹកទៀនស្រក់រលាយនោះជាទូទៅត្រូវបានគេបោះចោល ឬគ្មានការកែច្នៃសម្រាប់ប្រើប្រាស់ឡើងវិញនោះទេ។ ជាសាស្ត្រាចារ្យ ជាវិចិត្រករជើងចាស់ម្នាក់ និងជាស្ថាបនិកអង្គការក្រៅរដ្ឋាភិបាលម្នាក់ បានប្រមូលយកសំណល់ទាំងនោះមកប្រើប្រាស់ជាផ្ទាំងគំនូរចម្លាក់ប្លែកៗជាទីគាប់ភ្នែកមនុស្ស និងទេសចរណ៍។

សាស្ត្រាចារ្យ លោក ព្រហ្មវិចិត្រ ជាស្ថាបនិកអង្គការវិចិត្រករខ្មែរដើម្បីកុមារ បាននិយាយថា៖ «ពលរដ្ឋមួយចំនួនឆ្ងល់ថា តើចាំបាច់អីប្រមូលយកសំណល់ទៀនទាំងនោះ? ខ្ញុំថាខ្ញុំយកទៅ

បង្រៀនកូនក្មេងឲ្យចេះឆ្លាក់ បែរជាគាត់ថា ចុះគល់ឈើមួយគំនរមិនបង្រៀនឆ្លាក់ ទៅយករបស់នេះធ្វើអី ខ្ញុំថាអ្វីដែរគេចោលខ្ញុំចង់បានទាំងអស់ ខ្ញុំមិនចង់បាន ឬគាស់គល់ឈើនោះទេ ព្រោះខ្ញុំចង់ទុកឲ្យវាដុះបន្តទៀត»។

ផ្ទះឈើលើថ្មខាងក្រោមមួយ ជាទីតាំងសាលាបង្រៀនកុមារឲ្យចេះគូរគំនូរ និងឆ្លាក់ ដោយមិនគិតកំរៃមានទីតាំងស្ថិតនៅក្នុងភូមិក្រាំងពង្រ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ លោក ព្រហ្ម វិចិត្រ ឲ្យដឹងទៀតថា លោកចង់បង្កើតនូវបំណិនជីវិតដល់កុមារតាមរយៈសិល្បៈគំនូរបុរាណ និងគំនូរសម័យ វត្ថុឆ្នៃចេញពីស្លឹកឈើ ចម្លាក់ខ្លុកចម្លាក់ទៀន ទៅកាន់ក្មេងៗជំនាន់ក្រោយ ក្នុងស្រុកកំណើតរបស់លោកគ្រូ។

ដោយសារតែមានចិត្តស្រលាញ់គំនូរ និងនិស្ស័យពីកុមារភាពមក កូនក្មេងតូចៗជាសិស្សនៃអង្គការវិចិត្រករខ្មែរដើម្បីកុមារ បានចែករំលែកនូវបទពិសោធក្នុងការសិក្សារបស់ប្អូនៗទៅកាន់ក្មេងៗដទៃទៀត។

កុមារី វ៉ាន់ កន្និកា មានវ័យជាង១០ឆ្នាំជាសិស្សដែរសិក្សាក្នុងសាលាខាងលើអស់រយៈពេល ១ឆ្នាំ បាននិយាយថា៖ «ខ្ញុំគិតថាល្អសម្រាប់ខ្លួនឯង និងអាចជួយឲ្យមានចំណេះដឹងគ្រប់គ្រាន់ ព្រោះថា

> **គាលណាអារម្មណ៍ យើងមិនល្អ ធ្លាក់ មិនបាននោះទេ ទាល់តែ អារម្មណ៍យើងមូល ដូច្នេះ កូនក្មេងទាំងអស់យល់ច្បាស់ ពីក្បាច់នីមួយៗ។**

នេះជាមុខជំនាញមួយ។ មួយវិញទៀតស្រលាញ់តាំងពីមិនទាន់ចេះគូរគំនូរសោះរហូតដល់អាចចេះប្រើប្រាស់ឧបករណ៍បានយ៉ាងល្អ»។

ចំណែកយុវជនម្នាក់ទៀត លោក សេន សុម៉ី ជាសិស្សរបស់អង្គការខាងលើបាននិយាយថា៖ «សប្បាយចិត្តនៅពេលដែលចេះធ្វើចម្លាក់ទៀនទាំងនោះ មិននឹកស្មានថាខ្លួនអាចធ្វើបានដូចបច្ចុប្បន្ននេះទេ ហើយថ្ងៃអនាគតខ្ញុំចង់យកផ្នែកគំនូរ និងចម្លាក់ទៅរៀនបន្តទៀត»។

មុនពេលចម្លាក់ទៀនអាចចេញជារូបរាងបាន ដំបូងត្រូវយកទៀនទៅចំហុយឲ្យរលាយរួចច្រោះយកសំរាមចេញ និងចាក់ពុម្ព បន្ទាប់មកគេអាចយកវាទៅឆ្លាក់តាមរូបរាងដែលគេចង់បាន។ បើទោះបីជាចម្លាក់ទៀនសព្វថ្ងៃមិនទាន់បានដាក់ចូលក្នុងទីផ្សារនៅឡើយ លោក ព្រហ្មវិចិត្រ បានយកចម្លាក់ទាំងនោះទៅដាក់បង្ហាញក្នុងពិព័រណ៍នានា ជាពិសេសគឺបានដាក់តាំងនៅក្នុងសារមន្ទីរក្នុងទឹកដីសហរដ្ឋអាមេរិក។

សាស្ត្រាចារ្យវ័យ ៦៩ឆ្នាំរូបនេះ បញ្ជាក់ថាចម្លាក់ទៀនអាចរក្សាទុកបានរហូត និងមិនផ្លាស់ប្តូររូបរាងនោះទេ ប្រសិនបើយើងអាចរក្សាទុកនៅក្នុងតំបន់ដែលមានសីតុណ្ហភាពមិនក្តៅពេក ការពារមិនឲ្យមានសត្វកណ្តុរស៊ី។ មិនត្រឹមតែជាវត្ថុតាំងលម្អនោះទេ លោកសាស្ត្រាចារ្យគំនូរ និងចម្លាក់រូបនេះ បានរៀបរាប់អំពីលក្ខណៈពិសេសរបស់ចម្លាក់ទៀនថា វត្ថុនេះអាចធ្វើឲ្យសិស្សរបស់លោក ស្គាល់ច្បាស់ពីគំនូរ ចម្លាក់ និងផ្តល់ឱកាសឲ្យពួកគេយល់ពីការប្រើប្រាស់អារម្មណ៍ និងថាមពលទៅលើគំនូរនីមួយៗ។

លោក ព្រហ្ម វិចិត្រ បានបន្តថា៖ «បើកាលណាអារម្មណ៍យើងមិនល្អ ឆ្លាក់មិនបាននោះទេ ទាល់តែអារម្មណ៍យើងមូល ដូច្នេះកូនក្មេងទាំងអស់យល់ច្បាស់ពីក្បាច់នីមួយៗ ក្បាច់លៀន លោត លិប តើយើងត្រូវធ្វើរបៀបម៉េច?»។

ឆ្នាំ២០១៩នេះ អង្គការនេះត្រូវបានទទួលស្គាល់ស្របច្បាប់ បង្រៀនសិស្សបានជិត៨០នាក់ដោយសិស្សទាំងអស់អាចចូលរៀននៅអាយុណាក៏បាន ពោលឲ្យតែពួកគេអាចចេះកាន់ប៊ិច និងខ្មៅដៃ។ នាយកប្រតិបត្តិអង្គការខាងលើ សំណូមពរឲ្យប្រជាពលរដ្ឋគាំទ្រ សិល្បៈគំនូរខ្មែរ ដើម្បីផ្តល់ជាកម្លាំងចិត្តដល់វិចិត្រករខ្មែរបន្ថែមទៀត៕



*លោក ព្រហ្ម វិចិត្រ ស្ថាបនិកអង្គការវិចិត្រករខ្មែរ កំពុងបង្ហាត់បង្ហាញអំពីគំនូរ។ រូបភាព៖ អង្គការវិចិត្រករខ្មែរដើម្បីកុមារ*





*កូនសិស្សកំពុងរៀនអំពីចម្លាក់ទៀន។ រូបភាព៖ អង្គការវិចិត្រករខ្មែរដើម្បីកុមារ*



*កូនសិស្សក្នុងអង្គការកំពុងគូរគំនូរខ្មៅដៃ ខណៈពួកគេចង់យកផ្នែកគំនូរ និងចម្លាក់ទៅរៀនបន្តទៀតនាថ្ងៃអនាគត។ រូបភាព៖ អង្គការវិចិត្រករខ្មែរដើម្បីកុមារ*



*សកម្មភាពសប្បុរសជននាំយកអំណោយ និងអាហារ សម្ភារផ្សេងៗឧបត្ថម្ភដល់អង្គការវិចិត្រករខ្មែរដើម្បីកុមារ ដែលមានលោក ព្រហ្ម វិចិត្រ ជាស្ថាបនិក។ រូបភាព៖ អង្គការវិចិត្រករខ្មែរដើម្បីកុមារ*

# ស្ត្រីក្នុងវិស័យឯកជន កំពុងទទួលផលពីគម្រោងផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

*ដោយ៖ អរិយបុត្យ*

ស្ត្រីកម្មការិនីរោងចក្រ និង ស្ត្រីដែលកំពុងតែស្ថិតនៅក្នុងវិស័យឯកជនបានអះអាងថា ពួកគេបានឃើញនិងពិតជា បានទទួលប្រាក់ឧបត្ថម្ភតាមការប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា បើទោះបីជាមានបញ្ហាលើផ្នែកសេវាកម្ម និងការភ័ន្តច្រឡំខ្លះៗក៏ដោយ ។

ស្ត្រីវ័យ ៣១ ឆ្នាំ មួយរូបដែលកំពុងតែនាំកូនចុះពីលើឡាំប្រឺតា យកកូនមកចាក់ថ្នាំបង្ការនៅមន្ទីរពេទ្យជប៉ុន ដែលបានអះអាងថា ឈ្មោះ រឿង ចន្ថារ័ត្ន បានថ្លែងថា លោកស្រីគឺជាស្ត្រីមួយរូបដែលបានទទួលផលពីគម្រោងឧបត្ថម្ភប្រាក់របស់ រាជរដ្ឋាភិបាលតាមរយៈបេឡាជាតិរបបសន្តិសុខសង្គម ដែលគេតែងតែស្គាល់ជាទូទៅថា ប.ស.ស នោះ ។

លោកស្រីបញ្ជាក់ថា៖ «កាលពី៤ខែ មុន ខ្ញុំបានមកសម្រាលនៅទីនេះ (ពេទ្យជប៉ុន) អត់អស់លុយមួយរៀលទេ ហើយថែមទាំងបានលុយគួរសមខ្លះទៀត ពីប.ស.ស»។

លោកស្រីបានថ្លែងថា នៅមុនពេលដែលមកទទួលសេវាកម្មនេះ ចេះតែមានពាក្យថានេះថានោះ ពេលដែលយើង មកសម្រាលជាមួយនឹងសេវាកម្មប.ស.ស នេះ ប៉ុន្តែនៅពេលដែលលោកស្រីបានមកប្រើប្រាស់សេវាកម្មនេះ ឃើញថា មិនអី គឺអាចទទួលយកបាន។

លោកស្រីបានរៀបរាប់ថា ដំបូងវាដូចជារឿងសាំញ៉ាំបន្តិច ប៉ុន្តែដល់ពេលដែលយើងធ្លាប់ទៅ វាដូចជាមិនអីទេ ពោលគឺតាំងពីមកពិនិត្យពោះសម្រាល ហើយឥឡូវនេះដល់ពេលចាក់ថ្នាំបង្ការហើយ មិនដឹងយ៉ាងម៉េចទៀតទេ ចាំមើលសិន!។

លោកស្រីចន្ថារ័ត្ន បានថ្លែងឲ្យដឹងទៀតថា ជាទូទៅនៅពេលដែលយើងប្រើប្រាស់សេវាកម្មប.ស.សនេះ គឺពេលខ្លះ យើងមិនអាចធ្វើតាម ឬក៏ទទួលតាមសេវាកម្មដែលយើងចង់បាននោះទេ ពោលគឺមិនអាចទទួលសេវាកម្មវីអាយភី បានទេ ប៉ុន្តែសេវាកម្មផ្សេងៗ ដូចជាសម្រាលបន្ទប់ស្នាក់នៅ អាហារ ចាក់ថ្នាំ ការលាងសំអាតសព្វយ៉ាង គឺ អត់មានគិតប្រាក់ទេ សូម្បីតែវះកាត់។

លោកស្រីបានបញ្ជាក់ទាំងលេងសើចផងដែរថា៖ « ចាំមើលពេលចាក់ហើយ មិនដឹងបានលុយទៀតអត់ ពីព្រោះឮថា មានការឧបត្ថម្ភដល់កូន រហូតដល់ ២ ខួបទៀត ប៉ុន្តែមិនទាន់ដឹង»។



*ស្ត្រីកម្មការនីរោងចក្រដែលបានទទួលបានការសម្រាលកូនជាមួយនឹងសេវាកម្ម ប.ស.ស។ រូបភាព៖ ក្រសួងការងារ*

ស្ត្រីមួយរូបដែលទើបតែឆ្លងទន្លេរួចនៅមន្ទីរពេទ្យជប៉ុននេះដែរ ប៉ុន្តែបាននិយាយនៅក្នុងលក្ខខណ្ឌមិនបញ្ចេញអត្ត សញ្ញាណបានឲ្យដឹងថា នៅក្នុងនាមជាអ្នកបម្រើការនៅក្រុមហ៊ុនមួយដែលបានបង់ប្រាក់ទៅប.ស.សកន្លងមក គឺថា លោកស្រីបានទទួលផ្នែកខ្លះនៃសេវាកម្មនេះហើយ។

លោកស្រីបានរៀបរាប់ថា ជាទូទៅគឺអាចទទួលយកបាន បើទោះបីការចាត់ចែងការងារវាដូចជាសាំញ៉ាំបន្តិចក៏ដោយចុះ ។

លោកស្រីបានបញ្ជាក់ថា៖ «តាំងពីពិនិត្យពោះ រហូតដល់វះកាត់ និងបន្ទប់គេង គឺអត់មានអស់លុយមែន ហើយគេសន្យានឹងឲលុយ ដូចជា ៤០ ម៉ឺនរៀលមកក្នុងកុងថែមទៀត»។



*មន្ត្រី ប.ស.ស ចុះជួបផ្ទាល់ស្ត្រីឆ្លងទន្លេនៅមន្ទីរពេទ្យ។ រូបភាព៖ ក្រសួងការងារ*

កាលពីពេលថ្មីៗនេះ ដើម្បីងាយស្រួលទទួលបានសេវាកម្ម ប.ស.ស កាន់តែប្រសើរ ជាពិសេសលើសេវាកម្ម សម្រាលកូននេះ ប.ស.ស បានបង្ហាញនូវចំណុចមួយចំនួនដើម្បីឲ្យពួកគាត់អាចទទួលបានប្រាក់គោលនយោបាយឧបត្ថម្ភ ពីរាជរដ្ឋាភិបាល។

ដើម្បីទទួលបានប្រាក់ឧបត្ថម្ភបន្ថែមរបស់រដ្ឋាភិបាលឲ្យកាន់តែលឿន និងទាន់ពេលវេលា ប.ស.ស បានប្រាប់នូវចំណុចសំខាន់ៗចំនួន៤ ដល់ស្ត្រីដែលសម្រាលកូនរួច ដើម្បីធានានូវប្រសិទ្ធភាពដល់អ្នកទទួល។

ប.ស.ស បានឲ្យដឹងថា ចំណុចសំខាន់ទាំង៤ខាងលើ មានដូចជា៖ ១.កម្មករនិយោជិតជាស្ត្រីត្រូវមកបំពេញបែបបទនៅទីស្នាក់ការ ប.ស.ស ក្នុងរាជធានី ខេត្ត ក្នុងកំឡុងពេលយ៉ាងយូរ០៣ខែ មុនសម្រាលកូន។ ២.សាមីខ្លួនត្រូវភ្ជាប់មកជាមួយនូវលិខិតពិនិត្យផ្ទៃពោះដែលបានបញ្ជាក់កាលបរិច្ឆេទត្រូវសម្រាល( អេកូ) បណ្ណសមាជិក ប.ស.ស ឬប័ណ្ណមូលនិធិសមធម៌សុខាភិបាល អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទច្បាស់លាស់របស់សាមីខ្លួនដែលអាចទំនាក់ទំនងបាន។ ៣.ករណីសាមីខ្លួនមិនបានមកបំពេញបែបបទនៅ ប.ស.ស. ក្នុងកំឡុងពេលខាងលើ សាមីជនឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មកកាន់ ប.ស.ស. យ៉ាងយូរបំផុតមួយខែក្រោយថ្ងៃសម្រាលកូនី។ និងទី៤. សាមីខ្លួន ឬសាច់ញាតិត្រូវជូនដំណឹងមក ប.ស.ស តាមលេខទូរស័ព្ទទំនាក់ទំនងបន្ទាន់១២៨៦ ពេលដែលសម្រាកក្នុងមូលដ្ឋានសុខាភិបាល (មន្ទីរពេទ្យ) ដែលគ្មានភ្នាក់ងារ ប.ស.ស.។ ប្រភពដដែលបានបញ្ជាក់ថាចំពោះប្រាក់ឧបត្ថម្ភបន្ថែមរបស់រដ្ឋាភិបាល គឺផ្តល់ជូនចំពោះតែសមាជិក ប.ស.ស. ដែលបម្រើការងារក្នុងវិស័យឯកជនតែប៉ុណ្ណោះ។

សូមរម្លឹកទៀតថា ស្ត្រីនៅក្នុងវិស័យឯកជនដែលជាសមាជិក ប.ស.ស. ក្រោយពេលសម្រាលកូននឹងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមពី រដ្ឋាភិបាលកម្ពុជា ចំពោះអ្នកសម្រាលកូនមួយ ទទួលបានប្រាក់ចំនួន៤០ម៉ឺនរៀល, សម្រាលកូនភ្លោះ (ពីរនាក់) ទទួលបាន៨០ម៉ឺនរៀល។ ដោយឡែក អ្នកសម្រាលកូនភ្លោះ៣ (បីនាក់) ទទួលបានប្រាក់ចំនួន១២០ម៉ឺនរៀល។ លើសពីនេះទៀត ចំពោះអ្នកសម្រាលកូនភ្លោះ៣នាក់ គឺជាកូនរបស់សម្តេចនាយករដ្ឋមន្ត្រីនៃកម្ពុជា តេជោ ហ៊ុន សែន នឹងទទួលប្រាក់ឧបត្ថម្ភបន្ថែមទៀតចំនួន ៥លានរៀល រួមនិងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀតដែល ប.ស.ស ផ្តល់ជូន។

គិតត្រឹមខែសីហា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានបើកផ្តល់ជូនកម្មការិនីជាស្ត្រីសម្រាលកូនសរុបចំនួនប្រមាណជាង ១៩,៩ពាន់លានរៀល ស្មើនឹងស្ត្រីសរុបចំនួន ៤៩.៤៨០នាក់ ក្នុងនោះស្ដីស្រម្រាលកូន ភ្លោះពីរមានចំនួន៣១១នាក់ និងស្ត្រីសម្រាលបានកូនភ្លោះបីចំនួន០៤នាក់៕



# សម្តេចប៉ាបនឹងយាងមកបំពេញទស្សនកិច្ចនៅប្រទេសថៃនៅខែវិច្ឆិកា



*ដោយ៖ អរិយបុត្រ*

តាមការគ្រោងទុកសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ នឹងយាងមកបំពេញទស្សនកិច្ចជាផ្លូវការនៅក្នុងព្រះរាជាណាចក្រថៃ នៅក្នុងរង្វង់ខែវិច្ឆិកាខាងមុខនេះ! នេះបើតាមយោងតាមប្រភពពីព្រះសហគមន៍នៅក្នុងប្រទេសថៃ ។

ប្រភពដដែលបានឲ្យដឹងបន្តទៀតថា សម្តេចប៉ាបដែលជាមេដឹកនាំព្រះសហគមន៍កាតូលិកគ្រោងនឹងយាងមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រថៃជាផ្លូវការ រយៈពេលបីថ្ងៃពោលចាប់ពីថ្ងៃទី ២០ ដល់ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៩ តាមការគោរពអញ្ជើញជាផ្លូវការពីរាជរដ្ឋាភិបាលថៃ និង សភាលោកអភិបាលកាតូលិកថៃ ក្នុងឱកាសពិសេស ដែលព្រះសហគមន៍កាតូលិក នៅព្រះរាជាណាចក្រថៃកំពុងតែប្រារព្ធពិធីបុណ្យគម្រប់ ៣៥០ឆ្នាំ នៃការស្ថាបនាភូមិភាគនៃប្រទេសសៀម និង គម្រប់៥០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងរាជាណាចក្រថៃនិងសន្តអាសនៈ ហើយក៏ជាឆ្នាំនៃមហាមង្គល ព្រះរាជពិធីបរមរាជាភិសេកព្រះបាទសម្តេចមហាវជិរៈឡុងកន ព្រះមហាក្សត្ររបស់ប្រទេសថៃផងដែរនោះ។

ជាមួយគ្នានេះដែរ សម្រាប់វត្តមាន របស់សម្តេចប៉ាបនៅព្រះរាជាណាចក្រថៃនៅពេលខាងមុខនេះ នឹងក្លាយជាពេលវេលាលើកទីមួយ របស់ព្រះអង្គក្រោយសម្តេចប៉ាបយ៉ូហានប៉ូលទី ២បានយាងមកបំពេញទស្សនកិច្ចព្រះរាជាណាចក្រថៃម្តងកាលពី ៣៥ ឆ្នាំមុនតបតាមការអញ្ជើញពីរាជរដ្ឋាភិបាលថៃសម័យកាលនោះ។ ចាប់ពីការយាងមកលើកទី ១ របស់សម្តេចប៉ាប ក្នុងព្រះរាជាណាចក្រថៃគឺសន្តសម្តេចប៉ាប យ៉ូហាន ប៉ូលទី ២ នៅឆ្នាំ ១៩៨៤ រហូតដល់ពេលនេះ គឺ គ្រប់ ៣៥ ឆ្នាំ ហើយនៅពេលខាងមុខនេះនឹងក្លាយជាលើកទីមួយ នៅក្នុងសម័យកាលដែលព្រះសហគមន៍ស្ថិតនៅក្រោមមគ្គុទេសភាពរបស់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ផងដែរ។

ការយាងមកលើកនេះ ព្រះអង្គគ្រោងយាងមកក្នុងឋានៈជាភ្ញៀវរបស់រាជរដ្ឋាភិបាលថៃ ដោយដំណើរ ទៅសម្តេចប៉ាបគ្រោងនឹងយាងទៅកន្លែងផ្សេងៗ ដើម្បីសួរសុខទុក្ខគ្រីស្តបរិស័ទ និងប្រជាជនថៃ មុននឹងយាងបន្តទៅប្រទេសជប៉ុនពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៩។ នេះគឺពេលវេលា ដែលគួរឲ្យកត់សម្គាល់របស់ពិភពលោកចំពោះប្រទេសថៃ និងទ្វីប អាស៊ីយ៉ាងពិតប្រាកដ៕



*រូបភាព៖ លី សុវណ្ណា*



*លោក ឪពុក មួង រស់ ក្នុងពិធីអ*

# ដំណើរបូជានីយចរនៅលើ ទឹកដីមរណសាក្សី ជាតិកូរ៉េ

**ព្រះសហគមន៍កាតូលិកនៅភូមិភាគសេអ៊ូល បានរៀបចំកម្មវិធីបូជនីយចរ សម្រាប់គ្រីស្តបរិស័ទក្នុងប្រទេសរបស់ខ្លួនជាយូរឆ្នាំមកហើយ នៅតាមកន្លែងនានា នៃប្រវត្តិរបស់មរណសាក្សី ជាពិសេសកន្លែងដែលគេបានសម្លាប់សន្តបុគ្គលជាតិកូរ៉េទាំងនោះ។**



*ទីសក្ការដ្ឋាន Seosomun Martyrs' Shrine ជាទីដែលសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានមកអធិដ្ឋានពេលលោកទស្សនកិច្ចប្រទេសកូរ៉េ។ រូបភាព៖ ស៊ីអេសស៊ី*

*ដោយ៖ ខ*

នៅឆ្នាំ២០១៣ ព្រះសហគមន៍ភូមិភាគសេអ៊ូល បានបង្កើតខ្សែផ្លូវទីសក្ការដ្ឋាន "Seoul's Catholic Pilgrimage Routs" សម្រាប់ធ្វើបូជនីយចរ ដើម្បីលើកកម្ពស់ការប្រកាសដំណឹងល្អក្នុងប្រទេសកូរ៉េ ក៏ដូចជាការលើកកម្ពស់ការប្រកាសដំណឹងល្អនៅទ្វីបអាស៊ីផងដែរ។

ខ្សែផ្លូវនេះតាមទីកន្លែងទាំងនោះមានសក្ការដ្ឋានរបស់មរណសាក្សី សក្ការដ្ឋានជាព្រះវិហារ និងទីតាំងប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍ មានចំណាស់ប្រមាណជា២៣០ឆ្នាំមកហើយ។ សន្តអសនៈបានទទួលស្គាល់ខ្សែផ្លូវនេះ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨។

តាមការរៀបរាប់របស់គណៈកម្មការរៀបចំបានឲ្យដឹងថា ព្រះសហគមន៍ភូមិភាគសេអ៊ូលបានសន្មត់ យកខែកញ្ញា ជាខែសម្រាប់រំឭកមរណសាក្សីនៅកូរ៉េ ហើយប្រារព្ធសប្តាហ៍នៃធ្វើបូជានីយចរ។ នៅឆ្នាំ២០១៨ ក៏បានចាប់ផ្តើមកម្មវិធីបូជានីយចរ ជាអន្តរជាតិ។

លោកបូជាចារ្យ ប៉ូល រឿង ឆ័ត្រស៊ី បូជាចារ្យដឹកនាំក្រុមចូលរួមក្នុងដំណើរបូជនីយចរនេះមានប្រសាសន៍ថា ដោយសារនៅប្រទេសកូរ៉េមរណសាក្សីនីមួយៗគេសម្លាប់នៅកន្លែងណាព្រះសហគមន៍មាន ព្រះវិហារ ឬសក្ការដ្ឋាន នៅទីនោះដើម្បីឲ្យមនុស្សទៅកន្លែងនោះអធិដ្ឋាន នឹកឃើញវីរភាពរបស់សន្តបុគ្គល និងជំរុញពង្រឹងជំនឿអ្នកធ្វើបូជានីយចរ។

លោកបន្តថា ជាពិសេសកូរ៉េមិនចង់ធ្វើតែខ្លួនឯងទេ គេបានគិតថា ព្រះសហគមន៍កូរ៉េ គួរតែជាស្ពាន ដើម្បីចំលងឲ្យគ្រប់ប្រទេស នៅអាស៊ី ដែលមានមរណសាក្សីដែរ មានទំនាក់ទំនងគ្នា ដើម្បីពង្រឹង



*ក្រុមចម្រៀង ក្នុងពិធីបុណ្យរំឭកសន្តបុគ្គលនៅប្រទេសកូរ៉េ។*



...កិច្ចជា ក្នុងព្រះវិហារភ្នំកាត់ក្បាល។ *រូបភាពៈ លី សុវណ្ណា*



*រូបគំនូរសន្តបុគ្គលទាំង១២ នៅព្រះវិហារដ៏ចំណាស់ ដែលសន្ត ចែម ហ្សូត្រូវគេកាត់ក្បាល។ លី សុវណ្ណា*



*ក្រុមបូជានីយចរពីប្រទេសកម្ពុជា ថតជាមួយរូបសំណាកសន្តអន់ជ្រេគីម នៅភ្នំកាត់ក្បាល។ លី សុវណ្ណា*

អំពីការជំរុញ គ្រីស្តបរិស័ទ ឬការប្រកាសដំណឹងល្អថ្មីនេះ ឲ្យបានកាន់តែរីកចម្រើន និងល្អប្រសើរ។

អំពីគោលបំណងដែលក្រុមសមាជិកពីប្រទេសកម្ពុជាចូលរួមក្នុងដំណើរបូជាចរនេះ លោកបូជាចារ្យឆត្រសិរី បញ្ជាក់ថា៖ «យើងទៅដើម្បីសិក្សា និងរួមដំណើរជាមួយមរណសាក្សីនៅប្រទេសកូរ៉េដែរ។ ដំណើរនេះអាចមានប្រយោជន៍សម្រាប់អនាគត គឺរៀបចំកន្លែងបូជនីយចរ ឬសក្ការដ្ឋានរបស់ព្រះសហគមន៍នៅប្រទេសកម្ពុជា ឲ្យមានខ្សែជាប់គ្នា និងរៀបចំកម្មវិធីមួយដើម្បីឲ្យគ្រីស្តបរិស័ទ មានបូជនីយេសក៍ទាក់ទងនឹងមរណសាក្សីបានដែរ។ ម៉្យាងទៀត យើងបានឃើញវីរភាពរបស់មរណសាក្សីនៅប្រទេសកូរ៉េ ដែលយើងអាចយកគំរូមករៀបចំអំពីមរណសាក្សីនៅកម្ពុជាដែរ»។

បងស្រី ផារី ពីក្រុមបងស្រីឧបការគុណ ដែលបានចូលរួមក្នុងដំណើរបូជនីចរនេះបានមានប្រសាសន៍ថា៖ «រយៈពេល៩ថ្ងៃនេះជួយឲ្យគាត់បានស្គាល់ និងយល់ច្រើន ពីការសុខចិត្តបូជាជីវិតព្រោះតែជំនឿទៅលើព្រះយេស៊ូគ្រីស្តរបស់សន្តសន្តី។ បងស្រីយល់ឃើញថា គឺពិតមែន ឈាមរបស់មរណសក្សីបានបង្កើតផលផ្លែសព្វថ្ងៃនេះនៅប្រទេសកូរ៉េ។

ពេលដែលធ្វើដំណើរទៅតាមកន្លែងនីមួយៗ ដែលគេបានធ្វើទារុណ្ណកម្មលើមរណសាក្សីទាំងនោះ ដូនជីរូបនេះបញ្ជាក់ថា៖ «ខ្ញុំមានអារម្មណ៍ថា យើងជាគ្រីស្តបរិស័ទសព្វថ្ងៃនេះកំពុងតែពួតដៃគ្នា ដើម្បីធ្វើឲ្យរស់ឡើងវិញនូវសក្ខីភាពរបស់មរណសាក្សីកាលពីជំនាន់ដើម។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់បទពិសោធន៍ដ៏មានអត្ថន័យនេះ។ សូមសន្តបុគ្គលទាំងឡាយទូលអង្វរព្រះជាម្ចាស់ឲ្យគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា សូមឲ្យ មានជំនឿរឹងមាំពីមួយថ្ងៃទៅមួយថ្ងៃ ដោយចេះសុខចិត្តលះបង់ជីវិតផ្ទាល់ខ្លួនដើម្បីព្រះរាជ្យរបស់ព្រះអង្គផង»។

ចំណែក យុវនារី នៅ ម៉ាលីន ជាសមាជិកចូលរួមក្នុងដំណើរបូជនីយចរនេះដែរនិយាយថា ទីកន្លែងដែលនាងចាប់អារម្មណ៍ជាងគេនោះគឺ Dang-gogas Martyr’s Shrine។

ម៉ាលីនបញ្ជាក់ថា ដោយសារនៅទីនោះគឺបានដឹងអំពីសាច់រឿងនៃគ្រួសាររបស់លោកឪពុក Thomas Choe Yang-eop ដែលគ្រួសារគាត់ជាគ្រួសារមួយដ៏វិសុទ្ធដែលមានជំនឿទៅលើព្រះជាម្ចាស់ ជានិច្ចទោះបីជាពួកគាត់ទទួលរងនូវទុក្ខលំបាក។ លោកឪពុក Thomas Choe Yang-eop ក្លាហានក្នុងការបំពេញជំនឿរបស់គាត់ដោយបានចាកចេញពីគ្រួសារទាំងវ័យក្មេងដើម្បីទៅរៀន ហើយបានទទួលជោគជ័យដោយក្លាយជាបូជាចារ្យ។ នេះជាគំរូដ៏ល្អមួយសម្រាប់ជីវិតជាគ្រីស្តបរិស័ទ។

នៅក្នុងដំណើរបូជនីយចរនេះ តំណាងប្រទេសនីមួយៗដែលចូលរួមក្នុងនោះមាន កម្ពុជា វៀតណាម ហ្វីលីពីន ថៃ ភូមា ម៉ាឡេស៊ី តៃវ៉ាន់ ជប៉ុន និងសិង្ហបុរី។ កម្ពុជាក៏មានឱកាសធ្វើបទបង្ហាញអំពីព្រះសហគមន៍ និងមរណសាក្សីនៃប្រទេសរបស់ខ្លួនផងដែរ។ ក្នុងនោះព្រះសហគមន៍កម្ពុជា ក៏បានបង្ហាញពីព្រះសហគមន៍ និងដំណើរនៃការកសាងសំណុំឯកសារនៃមរណសាក្សីកម្ពុជា ដែលក្នុងនោះរួមមាន អំពីជីវិត លោកអភិបាល លោកបូជាចារ្យ បព្វជិត បព្វជិតា និងគ្រីស្តបរិស័ទដែលបានបូជាជីវិតក្នុងសម័យសង្គ្រាម និងវាលពិឃាត។

គណៈកម្មការមរណសាក្សីកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ដែលមានលោកអភិបាល អូលីវីយេជាប្រធាន។ លោកបូជាចារ្យ ឆ័ត្រសិរី មានប្រសាសន៍ថា៖ «ជីវិត ឬវីរភាពរបស់មរណសាក្សីនៅកម្ពុជានីមួយៗជាគំរូ សម្រាប់យើងជាគ្រីស្តបរិស័ទ ដោយសារ សេចក្តីក្លាហានរបស់គាត់ ដែលសុខចិត្តលះបង់ជីវិតដោយសារជំនឿ ថ្វាយទៅព្រះជាម្ចាស់។ ពេលយើងមានទុក្ខលំបាក គំរូរបស់ពួកគេជួយយើង និងផ្តល់ឲ្យយើងមានកម្លាំង។ មួយទៀត តាមជំនឿរបស់យើង យើងជឿថា យើងមានសន្តបុគ្គល ជាមនុស្សដែលមានគុណធម៌ខ្ពស់ ជាគំរូដល់យើង នៅជាមួយព្រះជាម្ចាស់ហើយ ក៏អាចអធិដ្ឋានព្រះជាម្ចាស់សម្រាប់យើងដែរ»។

ព្រះសហគមន៍ប្រការទទួលស្គាល់មរណសាក្សី នៅប្រទេសកូរ៉េជាច្រើនរយនាក់ តាំងពីឆ្នាំ១៩៨៤ មានសន្តអន់ជ្រេគីម ដែលមានឈ្មោះល្បីល្បាញ ក្រោយមកថ្មីៗនេះក្នុងឆ្នាំ២០១៤ បន្ថែមទៀត។ គ្រីស្តបរិស័ទប្រមាណជា ៨០០០នាក់ ដែលមានក្នុងបញ្ជីត្រូវគេសម្លាប់ចោលដោយសារតែជឿលើព្រះយេស៊ូ និងមានគ្រីស្តបរិស័ទជាច្រើនដែលសម្លាប់គ្មានកំណត់ហេតុព្រោះតែ ច្បាប់អាជ្ញា ប្រហារមុនរាយការណ៍តាមក្រោយ។ ការបៀតបៀននេះកើតឡើងក្នុងសតវត្សទី១៨ នៃរជ្ជកាល រាជវង្សចូសុន៕



*...រូបភាពៈ លី សុវណ្ណា*



*ក្រុមបូជានីយចរពីកម្ពុជា ថតជាមួយរូបសំណាកសន្តអន់ជ្រេគីម នៅភ្នំកាត់ក្បាល។ លី សុវណ្ណា*




*លោកបូជាចារ្យប៉ូល រឿង ឆ័ត្រសិរី បូជាចារ្យដឹកនាំក្រុមចូលរួមក្នុងដំណើរបូជនីយចរ។ រូបភាពៈ លី សុវណ្ណា*

# ព្រះសហគមន៍កាតូលិកកម្ពុជា ចូលរួមចំណែកបណ្តុះគ្រាប់ពូជល្អជូនដល់កម្ពុជា

*ដោយ៖ អរិយបុត្រ*



*លោកអភិបាលអូលីវីយេ មានប្រសាសន៍ក្នុងអង្គពិធី ចែកអំណោយដល់សិស្សនិទ្ទេសA និងសិស្សពូកែក្នុងស្រុកត្រាំកក់។ រូបភាពៈ ស៊ីអេសស៊ី*



*សិស្សពូកែប្រចាំស្រុកត្រាំកក់ថតជាមួយគណៈអធិបតី។ រូបភាពៈ ស៊ីអេសស៊ី*

នៅក្នុងចំណោមយុវសិស្សដែលបានប្រឡងសញ្ញាបត្រទុតិយភូមិបានជោគជ័យទាំងប្រមាណជា ៧៩.០៥២ នាក់ ក៏មានយុវសិស្សយ៉ាងហោចណាស់ជិតមួយរយនាក់ដែរ ដែលបានទទួលការអប់រំ នៅវិទ្យាល័យពីរដែលបណ្តុះបណ្តាលក្រោមកិច្ចសហការរវាងព្រះសហគមន៍កាតូលិកកម្ពុជាជាមួយនឹង ក្រសួងអប់រំ យុវជន និងកីឡា។

វិទ្យាល័យពីរដែលកំពុងតែបណ្តុះបណ្តាលក្រោមកម្មវិធីសិក្សាដែលគាំទ្រដោយព្រះ សហគមន៍កាតូលិកសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា គឺមានវិទ្យាល័យចំណេះទូទៅសន្តប្រហ្វង់ស្វ័រនៅចំការទៀង ស្រុកត្រាំកក់ ខេត្តតាកែវ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងវិទ្យាល័យចម្រើនវិជ្ជា នៅខេត្តព្រៃវែងនៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។

លទ្ធផលប្រឡងសញ្ញាបត្រទុតិយភូមិដែលបានផ្សព្វផ្សាយដោយក្រសួងអប់រំ យុវជន និង កីឡាបានបង្ហាញថា យុវសិស្សដែលកំពុងសិក្សានៅវិទ្យាល័យចំណេះទូទៅសន្តប្រហ្វង់ស័រចំនួនសរុប៣៦ នាក់ គឺបានប្រឡងជាប់ ១០០ភាគរយ នៅក្នុងនោះនិទ្ទេស A មាន១នាក់។ ដោយឡែកយុវសិស្សដែលសិក្សានៅវិទ្យាល័យចម្រើនវិជ្ជាវិញចំនួន ៨៥ នាក់ គឺក៏ជាប់ ១០០ភាគរយដែរ ហើយនៅក្នុងនោះគឺមានយុវសិស្សដែលទទួលបាននិទ្ទេស A នោះមានចំនួន ២ នាក់។

ក្នុងចំណោមយុវសិស្សជិត១០០ នាក់ដែលបានសិក្សានៅវិទ្យាល័យដែលទទួលការគាំទ្រពីព្រះសហគមន៍កាតូលិកទាំងពីរនេះ យុវសិស្សដែលបានប្រឡងជាប់ហើយមានពិន្ទុទាបនោះ គឺមានភាគរយតិចបំផុត ដោយភាគច្រើនគឺលទ្ធផលល្អបង្គួរ។

ក្រៅពីសាលាទាំងពីរនេះ មានយុវសិស្សមួយចំនួនដែលកំពុងតែសិក្សានៅវិទ្យាល័យបច្ចេកទេសសន្តប្រហ្វង់ស័រ នៅស្រុកត្រាំកក់ ខេត្តតាកែវ ទាំងអស់ក៏បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនេះលើជំនាញបច្ចេកទេស ផងដែរ។

គួររំលឹកថា រហូតមកដល់ពេលនេះ ក្រៅពីវិទ្យាល័យទាំងបីនេះ ព្រះសហគមន៍កាតូលិកនៅកម្ពុជាដែលមានបីភូមិភាគ គឺភ្នំពេញ កំពង់ចាម និង ខេត្តបាត់ដំបង បានចូលប្រឡូកនៅក្នុងវិស័យអប់រំ និង បណ្តុះបណ្តាលធនធានមនុស្សជាច្រើនកន្លែងនៅទូទាំងប្រទេស ចាប់តាំងពីថ្នាក់មតេយ្យសិក្សា ហើយនៅពេល ដែលចប់ការសិក្សាចំណេះទូទៅ ហើយនោះ ព្រះសហគមន៍កាតូលិក ក៏មានកម្មវិធីផ្តល់ជា អាហារូបករណ៍ សម្រាប់ជួយដល់យុវសិស្សក្រីក្រ ដែលបានស្វែងរកការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ ការផ្តល់ជាកន្លែងស្នាក់នៅជូនពួកគេថែមទៀត ដោយក្នុងនោះនៅមិនទាន់រាប់បញ្ចូលទាំងសាលាបច្ចេកទេសជាច្រើនកន្លែងទៀត៕



# អដ្ឋិធាតុសន្តីហ្សេលី និងសន្តល្វីស មកដល់កម្ពុជា



*ដោយ៖ ស៊ីអេសស៊ី*

អដ្ឋិធាតុរបស់សន្តល្វីស និងសន្តីហ្សេលី បានចាកចេញពីកម្ពុជាហើយ កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩។រយៈ ពេលមួយខែដែលសន្តសន្តីជាគូស្រករ នេះបានតម្កល់នៅក្នុងប្រទេសកម្ពុជា និងបានធ្វើដំណើរទៅកន្លែងជាច្រើននៅក្នុងប្រទេសមួយនេះ។

វត្តមានអដ្ឋិធាតុនៃសន្តសន្តីទាំងពីរ បានពោរពេញដោយអំណរ សម្រាប់គ្រួសារគ្រីស្តបរិស័ទនៅកម្ពុជា ដែលមានគំរូសម្រាប់ជំនឿជាគូស្វាមីភរិយា ដែលជាសន្តសន្តី។

នៅក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ នៅតាមកន្លែងនីមួយៗ មានពិធីទទួលយ៉ាងអ៊ឹកអធឹក មានក្បួនដង្ហែជាឱឡារិក អភិបូជាទិវាគ្រួសារ បោះជុំរំការត្រាស់ហៅ អធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ ការជួបជុំគូស្រករ ដើម្បីរំឭកពាក្យសច្ចា មានការអប់រំពីសំណាក់លោកអភិបាល អូលីវីយេ ដែលមានរំលេចឲ្យគ្រីស្តបរិស័ទបានឃើញនូវវីរភាព គំរូរបស់សន្តសន្តីទាំងពីរ កាន់តែច្បាស់ថែមទៀត ដែលអ្នកទាំងពីរមានជំនឿយ៉ាងមាំមួន និងជ្រាលជ្រៅបំផុតលើព្រះជាម្ចាស់។

អដ្ឋិធាតុបានមកដល់ប្រទេសកម្ពុជា នាព្រឹកថ្ងៃទី២៦ ខែសីហា ហើយបានធ្វើដំណើរទៅកាន់ព្រះវិហារសន្តីតេរេសា នៅព្រែកប្បាស់ មុនគេ ដោយអ្នកទាំងពីរជាមាតាបិតារបស់សន្តីតេរេសា។ ទៅទីនោះ លោកបានអប់រំស្តីពី "គូស្វាមីភរិយាដ៏វិសុទ្ធ" នៃសន្តសន្តី ជាគំរូសម្រាប់គ្រួសារទាំងអស់។ លោកអភិបាលថា គេទាំងពីរស្រឡាញ់ព្រះជាម្ចាស់យ៉ាងខ្លាំង ណែនាំកូនឲ្យស្គាល់ព្រះជាម្ចាស់ ព្រះនាងម៉ារី និងព្រះយេស៊ូជាដើម។ ចេះគោរពគ្នាទៅវិញទៅមក យកចិត្តទុកដាក់ស្រឡាញ់កូនអប់រំកូនៗ ឲ្យមានចំណេះដឹង។ លោកបន្តថាគូស្រករនេះសាមញ្ញធម្មតា គេចេះតស៊ូចិញ្ចឹមជីវិតស្រឡាញ់ទៅវិញទៅមក ស្រឡាញ់កូន និងស្រឡាញ់ព្រះជាម្ចាស់ខ្លាំងបំផុត។

ថ្ងៃទី២៧ ខែសីហា អដ្ឋិធាតុក៏បន្តដំណើរទៅព្រះសហគមន៍ចំការទៀង នៅទីនោះ មានការទទួលយ៉ាងឱឡារិកបំផុតជាមួយភ្លេងប្រពៃណីខ្មែរ មានអគ្គសញ្ញាជ្រមុជទឹក លាបថ្វាស មានការសម្តែងយ៉ាងអស្ចារ្យអំពីព្រះនាងម៉ារីឡើងស្ថានបរមសុខ។ គ្រីស្តបរិស័ទបានបន្តអធិដ្ឋាន នៅមុខធាតុនេះជាប់ជានិច្ច។

ថ្ងៃទី២៨ ខែសីហា សន្តសន្តីទាំងពីរ បន្តដំណើរទៅតំបន់កំពត គឺនៅព្រះសហគមន៍សន្តយ៉ូសែបជុំគីរី មានអភិបូជា និងទស្សនាអំពីជីវិតរបស់សន្តសន្តីទាំងពីរ។ នៅទីនេះ លោកអភិបាលអូលីវីយេ បានអប់រំគ្រីស្តបរិស័ទស្តីអំពី "គ្រួសារគំរូមួយសម្រាប់ថ្ងៃនេះ"។ លោកអភិបាលបានបង្ហាញអំពីជីវិតក្នុងសេចក្តីស្រឡាញ់យ៉ាងជ្រៅនៃលោក ល្វីស និងលោកស្រីហ្សេលី មានចំពោះគ្នាទៅវិញទៅមក ជាគំរូយ៉ាងពិតប្រាកដ។ លោកថា បើឪពុកម្តាយចេះស្រឡាញ់គ្នាយ៉ាងពិតប្រាកដ កូនៗយកគំរូតាម ដោយចេះស្រឡាញ់គ្នាយ៉ាងខ្លាំងដែរ ។ ដែលណែនាំឲ្យយើងមើលឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង។ ច្បាស់ណាស់ព្រះអង្គជាសេចក្តីស្រឡាញ់។ ព្រះអង្គចងសម្ពន្ធមេត្រីជាមួយប្រជារាស្ត្ររបស់ព្រះអង្គ។ លោកអភិបាលក៏បានបញ្ជាក់ដែរ គឺសន្តីតេរេសា បានរកឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់តាមគំរូ ដែលឪពុកម្តាយស្រឡាញ់គាត់ផងដែរ។

នៅថ្ងៃទី២៩ ខែសីហា សន្តីសន្តទាំងពីរ បានទៅដល់ក្រុងព្រះសីហនុ គឺព្រះវិហារសន្តមីកាអែល ដែលជាព្រះវិហារតែមួយគត់ដែលនៅសល់ពីសង្គ្រាម ដែលខ្មែរក្រហមមិនបានបំផ្លាញ។ ទោះបីផ្លូវពិបាក ចរាចរណ៍ចង្អៀត ក៏ដោយសន្តសន្តីគូស្រករនេះបានទៅដល់ ហើយមានការស្វាគមន៍យ៉ាងល្អប្រសើរ។ មានអធិដ្ឋាន មានការគោរព អដ្ឋិធាតុ និងអគ្គសញ្ញាជ្រមុជទឹក។ លោកអភិបាលអូលីវីយេ ក៏បានអប់រំណែនាំគ្រីស្តបរិស័ទស្តីអំពី "ការអប់រំប្រៀនប្រដៅកូនចៅ"។

ថ្ងៃទី៣០ ចាកចេញពីក្រុងព្រះសីហនុ មករាជធានីភ្នំពេញ គឺបានចូល ព្រះសហគមន៍ព្រែងត្រយឹង ដើម្បីគ្រីស្តបរិស័ទបានអធិដ្ឋាន និងគោរព។ បន្ទាប់មកបន្តដំណើរមកព្រះសហគមន៍អរិយក្សត្រ។ ក្នុងពេលនោះ ក៏មានអគ្គសញ្ញាអាពាហ៍ពិពាហ៍សម្រាប់គូស្រករថ្មី ពួកគេបានប្រកាសពាក្យសន្យាចំពោះព្រះជាម្ចាស់ ព្រះសហគមន៍ និងនៅមុខគ្រួសារដែលជាគំរូពិសេស ជាគ្រួសារដ៏វិសុទ្ធ គឺសន្តល្វី និងសន្តីហ្សេលីម៉ាតាំង។ លោកអភិបាលអូលីវីយេ បានលើកឡើងអំពីគំរូម្តងទៀតនៃសន្តសន្តីទាំងពីរ។

ថ្ងៃទី៣១ ខែសីហា និងថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ អដ្ឋិធាតុ របស់សន្តសន្តីទាំងពីរ បានមកដល់ព្រះវិហារសន្តយ៉ូសែប ភ្នំពេញ ដោយមានកិច្ចស្វាគមន៍យ៉ាងឱឡារិក ពីសំណាក់គ្រីស្តបរិស័ទទាំងអស់ ដោយអំណរ។ លោកអភិបាល បានលើកយកនូវអ្វីដែលគ្រួសារនេះបានយកជាទីពឹង គឺព្រះជាម្ចាស់ជាឪពុកដ៏ល្អ។ គ្រួសារនេះដែលបានពឹងផ្អែកទាំងស្រុងក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ក្រោយមកពេលរសៀលថ្ងៃទី០១ ខែកញ្ញា សន្តសន្តីទាំងពីរបានទៅដល់ព្រះវិហារចំប៉ា ដែលមានការទទួលស្វាគមន៍ យ៉ាងខ្លាំងបំផុត នៅតាមផ្លូវភូមិដ៏តូច ដែលពោរពេញដោយមនុស្ស ដែលស្រេកឃ្លាន ក្នុងការអធិដ្ឋាន និងពាល់ធាតុសន្តសន្តីទាំងពីរ។ នៅក្នុងព្រះវិហារ មានគ្រួសារចំនួន៥៣គូ បានចូលរួមប្រកាសពាក្យសច្ចាឡើងវិញ នឹករឭកអំពីអគ្គសញ្ញាអាពាហ៍ពិពាហ៍របស់ខ្លួន ដែលបានរៀបការពី២០ឆ្នាំដល់៥០ឆ្នាំ។ ក្នុងពេលនោះលោកអភិបាលអូលីវីយេ បានរំឭកអំពីគំរូរបស់សន្តសន្តីគឺយកព្រះជាម្ចាស់ជាចម្បងក្នុងជីវិតរបស់គេ។ លោកថានៅទីនេះគ្រីស្តបរិស័ទបានតស៊ូខ្លាំងណាស់ ដោយសារមានជំនឿលើព្រះជាម្ចាស់ ព្រះអង្គស្រឡាញ់យើង។

ថ្ងៃទី០២ ខែកញ្ញា បានទៅដល់មណ្ឌលសកម្មភាពទន្លេបាសាក់ដែលមានគ្រីស្តបរិស័ទទទួលដោយអំណរ នៅព្រះវិហារទួលក្រសាំង និងជ្រៃធំ។ លោកអភិបាលបានលើកយកគំរូរបស់សន្តសន្តីទាំងពីរ ដោយរំឭកឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់គឺគ្រួសារដែលអធិដ្ឋាន ស្រឡាញ់ និងបម្រើ។

ពីថ្ងៃទី០៣ដល់ទី០៨អដ្ឋិធាតុបានមកដល់ព្រះវិហារភ្នំពេញថ្មី និងបានតម្កល់នៅទីនោះ រហូតដល់ថ្ងៃទី០៨ ខែកញ្ញា មុនចេញដំណើរទៅបាត់ដំបង។ នៅទីនេះ មានកម្មវិធីជាច្រើន ដែលសន្តសន្តីទាំងពីរបានជួប គឺទិវាការត្រាស់ហៅថ្នាក់ជាតិ ដែលមាន យុវជនយុវានារីជាង៣០០នាក់ចូលរួម ទិវាគ្រួសារ ដែលមានគ្រួសារជិត២០០គ្រួសារ ដែលអធិដ្ឋាននៅចំពោះមុខអដ្ឋិធាតុ នឹងព្រះជាម្ចាស់ និងទទួលព្រះពរ ពាក្យអប់រំប្រៀនប្រដៅរបស់លោកអភិបាល ដែលមានសន្តល្វីស និងសន្តីហ្សេលីម៉ាតាំងជាគំរូ ក្នុងការកសាងគ្រួសារប្រកបដោយសុភមង្គល និងជំនឿរឹងមាំលើព្រះជាម្ចាស់។

ក្រោយពីបានធ្វើដំណើទៅភូមិភាគបាត់ដំបង និងកំពង់ចាម អដ្ឋិធាតុបានមកដល់ព្រះវិហារបឹងទំពុន នៅទីនេះមានគ្រួសារជាច្រើនប្រកាសអំពីពាក្យសច្ចាឡើងវិញ តាមអគ្គសញ្ញាជ្រមុជទឹក។ នាឱកាសនោះលោកអភិបាលអូលីវីយេក៏បានរំឭកគូស្រករទាំងអស់ឲ្យយកចិត្តទុកដាក់ និងបំពេញបេសកកម្មរបស់ខ្លួនជាគូស្រករ គ្រីស្តបរិស័ទ។

អដ្ឋិធាតុចាកចេញពីកម្ពុជា នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ដោយឆ្លងកាត់ប្រទេសថៃ ជាប្រទេសមួយ ដែលសម្តេចប៉ាបនឹងមកបំពេញទស្សកិច្ចនាខែវិច្ឆិកាខាងមុខ ផ្សេងពីការរំពឹងទុក ដែលអដ្ឋិធាតុត្រូវចេញ និងឆ្លងកាត់ប្រទេសវៀតណាម។ ក្នុងរយៈមួយខែនេះ ពិតជាពេលវេលាវិសេសវិសាលណាស់ សម្រាប់សន្តសន្តីជាគូស្វាមីភរិយាទាំងពីរ ដែលបានមកដល់កម្ពុជាឲ្យគ្រីស្តបរិស័ទបានស្គាល់ គំរូដ៏អស្ចារ្យ នៃអ្នកទាំងពីរ ព្រោះថាកម្ពុជាបាត់បង់នូវគំរូល្អ ក្នុងជំនឿ ក្នុងការរស់នៅជាគ្រួសារ ដែលអាចឲ្យអ្នកជំនាន់ថ្មីកសាងគ្រួសារប្រកបដោយសេចក្តីសុខ។ បាត់បងឫសគល់នៃគ្រួសារ ដោយសារសង្គ្រាម ជាពិសេសក្នុងរបបអាវខ្មៅប៉ុលពត។

# អដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលីម៉ាតាំង នៅលើទឹកដីក្រុងអង្គរ

*ដោយ៖ លី សុវណ្ណា*

អដ្ឋិធាតុរបស់សន្ត លូវីស និងសន្តីហ្សេលីម៉ាតាំងបានធ្វើដំណើរតាមព្រះសហគមន៍មួយចំនួនក្នុងព្រះសហគមន៍ ភូមិភាគបាត់ដំបង ពីថ្ងៃទី៨ ខែកញ្ញា ពេលរសៀល ដល់ថ្ងៃទី១២ពេលព្រឹក ខែកញ្ញា។ អដ្ឋិធាតុបានចាកចេញពីព្រះវិហារសន្តសិលានិងសន្តប៉ូល ភ្នំពេញថ្មីវេលាប្រមាណម៉ោង១១ ព្រឹក និងបានចូលដំបូងទៅព្រះវិហាសន្តសិលា ក្រុងកំពង់ឆ្នាំង ដើម្បីឲ្យគ្រីស្តបរិស័ទ គោរព និងអធិដ្ឋាន បន្ទាប់មកក៏បន្តដំណើរ ទៅព្រះវិហារក្នុងក្រុងពោធិសាត់ ដោយទទួលស្វាគមន៍ពីសំណាក់លោកបូជាចារ្យ បងស្រី និងគ្រីស្តបរិស័ទ។

ក្នុងឱកាសនោះលោកបូជាចារ្យម៉ាណុច ឯកា បានពន្យល់ និងរៀបរាប់អំពីជីវិតរបស់សន្តី និងសន្ត២រូបនេះ។ លោកថា៖ «សន្ត សន្តីទាំងពីរដែលជាគំរូយ៉ាងល្អវិសេសសម្រាប់ជីវិតគ្រីស្តបរិស័ទជាគ្រួសារ។ ពួកមានជំនឿយ៉ាងមាំមួនលើព្រះជាម្ចាស់។ សូមយកគំរូតាមអ្នកទាំងពីរ និងអធិដ្ឋានតាមរយៈពួកឲ្យជួយយើង និងគ្រួសារយើងដែរ»។

បន្ទាប់មកលោកបូជាចារ្យ រួមជាមួយគ្រីស្តបរិស័ទអធិដ្ឋាន និងបានគោរពធាតុរបស់សន្តសន្តីទាំងពីរ ហើយអដ្ឋិធាតុក៏បន្តដំណើរទៅខេត្តបាត់ដំបង។

អដ្ឋិធាតុបានតម្កល់នៅព្រះវិហារព្រះនាងម៉ារីឡើងស្ថានបរមសុខ ចំនួនពីរយប់ដើម្បីឲ្យគ្រីស្តបរិស័ទបានគោរព និងអធិដ្ឋាន រហូតដល់ព្រឹកថ្ងៃទី១០ ខែកញ្ញា។ ក្នុងធម្មទេសនានៃពិធីអភិបូជានារសៀលថ្ងៃទី៩ ខែកញ្ញា ក្នុងនាមលោកអភិបាលគីកេ ហ្វីកាវេដូ លោកបូជាចារ្យ តូតែត តំណាងពេញសិទ្ធិលោកអភិបាលមានប្រសាសន៍ថា៖ «គ្រួសាររបស់យើងអាចក្លាយជាគ្រួសារដ៏វិសុទ្ធ និងជាសំបុកដ៏កក់ក្តៅសម្រាប់សមាជិកក្រុមគ្រួសារទាំងអស់»។



*អដ្ឋិធាតុរបស់សន្តលូវីស និងសន្តីហ្សេលី បានមកដល់ខេត្តសៀមរាប។ រូបភាព៖ ស៊ីអេសស៊ី*

លោកបន្តថា៖ «សន្តសន្តីជាអ្នកមានសុភមង្គលពេញលក្ខណៈជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខ។ ហេតុនេះ សុភមង្គល មិនសម្រេចទៅលើទ្រព្យសម្បត្តិស្តុកស្តម្ភ និងមុខមាត់នៅក្នុងសង្គមទេ។ សុភមង្គលរបស់ក្រុមគ្រួសារ សម្រេចទៅលើសេចក្តីសុខក្នុងក្រុមគ្រួសារ ការគោរពគ្នា និងការអធ្យាស្រ័យឲ្យគ្នាទៅវិញទៅមកនោះទេ។ នេះជាប្រភពនៃសុមភង្គលក្នុងក្រុមគ្រួសារ។

លោកបូជាចារ្យ បានដាស់តឿនគ្រីស្តបរិស័ទទាំងអស់អប់រំកូនៗរបស់ដោយគំរូផ្ទាល់ ច្រើនជាងនិយាយ គឺអប់រំកូនៗឲ្យយកព្រះជាម្ចាស់ជាចំបង ស្រឡាញ់ព្រះសហគមន៍ ជួយអ្នកដទៃ។ លោកថាសូមបងប្អូន រួមទាំងគណកម្មការព្រះសហគមន៍ជួយធ្វើជាគំរួសម្រាប់កូនៗ។ ធ្វើដូចនេះយើងនាំព្រះសហគមន៍ទៅជាព្រះសហគមន៍ដ៏វិសុទ្ធ ដែលមានគ្រួសារជាច្រើនដ៏វិសុទ្ធ។ សូមយកសន្តលូវីស និងសន្តីហ្សេលីជាសេចក្តីសង្ឃឹម និងគំរូដើម្បីយើងទាំងអស់គ្នាបានជិតស្និតជាមួយព្រះជាម្ចាស់។



*អដ្ឋិធាតុរបស់សន្តលូវីស និងសន្តីហ្សេលី បានមកដល់ខេត្តពោធិសាត់។ ស៊ីអេសស៊ី*

គ្រីស្តមានឱកាសដើម្បីអធិដ្ឋាននៅចំពោះមុខអដ្ឋិធាតុរបស់សន្តសន្តីទាំងពីររហូតដល់ព្រឹកថ្ងៃទី១០ ខែកញ្ញា។ អដ្ឋិធាតុក៏បានបន្តដំណើរទៅព្រះសហគមន៍ចំណោមព្រះវិហារសន្តីតេរេសា ដែលជាបុត្រីរបស់សន្តសន្តីទាំងពីរ។ លោកគ្រូយ៉ាតដែលជាគណៈកម្មការព្រះសហគមន៍ចំណោមមានប្រសាសន៍ទាំងរំភើបដោយអរព្រះគុណព្រះជាម្ចាស់ដែលមានប្រទានពេលវេលាឲ្យសន្តសន្តីទាំងពីរនេះបានមកដល់ព្រះវិហារសន្តីតេរេសាចំណោមដែលនៅដាច់ស្រយាលមួយនេះ មកសួរសុខទុក្ខគ្រីស្តបរិស័ទទាំងអស់គ្នា ពិតជារំភើបណាស់។

លោកថា៖ «យើងខ្ញុំនឹងយកគ្រួសារនេះជាគំរូ ព្រោះព្រះជាម្ចាស់ប្រទានឲ្យពួកគាត់ មានជំនឿ និងជាសន្តសន្តី»។

នៅថ្ងៃដដែលអដ្ឋិធាតុបានបន្តដំណើរទៅកាន់ខេត្តសៀមរៀប នៅទីនោះមានគ្រីស្តបរិស័ទ និងក្រុមគ្រួសារជាច្រើនបានជួបជុំគ្នា ជាស្រេចចាំទទួលស្វាគមន៍គូស្រករមួយគូនេះ។ ក្នុងអភិបូជាលោកបូជាចារ្យតែតតំណាងពេញសិទ្ធិលោកអភិបាលគីកេ បានប្រកាស នៅចំពោះមុខព្រះសហគមន៍ថា លោក ឆេង ម៉ាប់ និងភរិយា ជាអ្នកសម្របសម្រួលគណៈកម្មការសម្រាប់ក្រុមគ្រួសារគ្រីស្តបរិស័ទភូមិភាគបាត់ដំបងទាំងមូល។

លោក ឆេង ម៉ាប់ បានគិតគូរគម្រោងការសម្រាប់ក្រុមគ្រួសារក្នុងភូមិភាគរួចហើយដែរ លោកនឹងដាក់ឈ្មោះគម្រោងថា «លូវី និងហ្សេលី»។ លោកម៉ាប់បញ្ជាក់ថា គោលបំណងចំបង សម្រាប់គម្រោងនេះគឺផ្អែកលើអគ្គសញ្ញា អាពាហ៍ពិពាហ៍ ដែលមានខសន្យាទាំង៣។ គឺរិះគិតអំពីការកសាងការទំនាក់ទំនងដៃគូ។ គំរូនៃការអប់រំកូនដោយស្រលាញ់ និងមើលអ្នកដទៃក្នុងផ្លូវវិជ្ជមាន ស្រលាញ់ព្រះសហគមន៍ អធិដ្ឋាន ចូលព្រះវិហារបង្រៀនកូនតាមគំរូរបស់យើងផ្ទាល់។ មួយទៀត គឺ បង្កើតសហគមន៍គ្រួសារដ៏តូចមួយដែលអាចជួយគ្នាទៅវិញទៅមក តាមគំរូគ្រីស្តបរិស័ទពីជំនាន់ដើម។

ក្រោយពីបានស្នាក់នៅក្នុងភូមិភាគបាត់ដំបង រយៈពេល៤ថ្ងៃ សម្រាប់គ្រីស្តបិរស័ទមានពេលគោរពអធិដ្ឋានរួមជាមួយគ្នា នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ បានចាកចេញពីខេត្តសៀមរាបទឹកដីក្រុងអង្គរ នៃភូមិភាគបាត់ដំបងបន្តដំណើរទៅកាន់ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម៕



*អដ្ឋិធាតុរបស់សន្តលូវីស និងសន្តីហ្សេលី បានមកដល់ខេត្តកំពង់ឆ្នាំង*



*អដ្ឋិធាតុរបស់សន្តលូវីស និងសន្តីហ្សេលី បានមកដល់ខេត្តបាត់ដំបង*



*អដ្ឋិធាតុរបស់សន្តលូវីស និងសន្តីហ្សេលី មកដល់ចំណោម*




*យុវជន យុវនារីនៃព្រះសហគមន៍តំបន់មណ្ឌលគិរី នៃភូមិភាគកំពង់ចាម ធ្វើដំណើរបូជនីចរដោយជិះកង់រិះគិតអំពីជំនឿ។ រូបភាព៖ សហការី*

# ពង្រឹងជំនឿបន្ថែមដល់យុវជនដោយដំណើរ ជិះកង់ទៅតាមព្រះសហគមន៍

*ដោយ៖ ប្រេងតាំ*

យុវជន យុវនារីនៃព្រះសហគមន៍តំបន់មណ្ឌលគិរី នៃភូមិភាគកំពង់ចាម ចំនួន២៨នាក់ ដែលដឹកនាំ ដោយលោកបូជាចារ្យ ប្រ្វង់ស្វ័រ អេមេល្យូដាល បានធ្វើដំណើរបូជនីចរដោយជិះកង់រិះគិតអំពីជំនឿដែលមានរយៈចំងាយប្រមាណ១០០គីឡូម៉ែត ដោយធ្វើដំណើរទៅតាមព្រះសហគមន៍ចំនួន៣កន្លែងក្នុងខេត្តកំពង់ចាម។

លោកបូជាចារ្យប្រ្វង់ស្វ័រ អេមេល្យូដាល ជាអ្នកដឹកនាំក្រុមយុវជនក្នុងកម្មវិធីបូជនីចរមានប្រសាសន៍ថា គោលដៅនៃកម្មវិធីនេះ គឺដើម្បីឲ្យយុវជនខិតខំតស៊ូនឹងភាពហត់នឿយ មានជំនឿមាំមួនលើព្រះជាម្ចាស់ និងឲ្យពួកគេចេះស្រឡាញ់គ្នាទៅវិញទៅមក។

នៅក្នុងឱកាសនោះ លោកបូជាចារ្យបានបង្រៀនយុវជន យុវនារីអំពីជីវិតរបស់សន្តិក្លារ៉ា ដែលមានជំនឿយ៉ាងមុតមាំទៅលើព្រះជាម្ចាស់។ នាងបានក្លាយជាពន្លឺសម្រាប់អ្នកដែលអស់សង្ឃឹម។

សន្តិក្លារ៉ាជាយុវនារីម្នាក់ កើតនៅប្រទេសអ៊ីតាលី។ នៅពេលនាងមានអាយុ១៧ ឆ្នាំ នាងបានកើតជំងឺមហារីក ប៉ុន្តែនាងបានតស៊ូជាមួយវា ដោយមានជំនឿយ៉ាងមុតមាំទោះបីដឹងថា ២ ឆ្នាំក្រោយទៀតនាងនឹងស្លាប់ក៏ដោយ។

> **“មនុស្សយើងម្នាក់តែងតែមានបញ្ហានៅក្នុងជីវិតមិនថាតូចឬធំ យើង ដោះស្រាយតាមសន្តិវិធី ហើយនឹងអធិដ្ឋាន ផ្ញើកិច្ចការទាំងអស់ទៅព្រះជាម្ចាស់”**

លោកបូជាចារ្យមានប្រសាសន៍អំពីសន្តិរូបនេះយ៉ាងនេះថា៖ «គាត់រួមជាមួយព្រះយេស៊ូយ៉ាងស្និទ្ធស្នាល ហើយគាត់មានជំនឿរឹងមាំលើព្រះយេស៊ូ ដោយមិនខ្លាចសេចក្តីស្លាប់ ហើយគាត់ស៊ូទ្រាំជាមួយជំងឺរបស់គាត់ ហើយគាត់ទៅជាពន្លឺសម្រាប់អ្នកដទៃ»។

យុវជនលោក ឡែម បាននិយាយថា ដំណើរបូជនីយចរនេះ បានធ្វើឲ្យគាត់ ផ្លាស់ប្តូរការគិតរបស់គាត់ក្នុងជីវិតរស់នៅ។ ឡែម និយាយថា៖ «ជីវិតរបស់ខ្ញុំពីមុន មានរឿងតិចតួចគឺខ្ញុំឆាប់អស់សង្ឃឹម មិនមានជំនឿជឿជាក់លើខ្លួនឯង។ ក្រោយពេលខ្ញុំចូលរួមកម្មវិធីនេះ ធ្វើឲ្យខ្ញុំមានជំនឿជឿជាក់លើខ្លួនឯង ហើយមានជំនឿលើព្រះជាម្ចាស់កាន់តែខ្លាំងថែមទៀត»។

កម្មវិធីបូជនីយចរដោយជិះកង់នេះបានធ្វើឡើងរយៈពេលបីថ្ងៃពីថ្ងៃទី៧-៩ តុលា ២០១៩ ដោយជិះកង់ពីព្រះសហគមន៍កំពង់ចាមក្រុងទៅព្រះសហគមន៍ក្តុលលើ និងបញ្ចប់ដំណើរទៅព្រះសហគមន៍កោះរការ។

ក្លៃ ប៊ីម មកពីព្រះសហគមន៍ប៊ូស្រា ឲ្យដឹងថា ក្នុងរយៈពេល៣ថ្ងៃនេះ នាងបានចាប់អារម្មណ៍ជាខ្លាំងនូវជីវិតរបស់សន្តិក្លារ៉ាដែលហៀបនឹងស្លាប់ហើយនេះ គាត់បានឲ្យឪពុកម្តាយប្រើពាក្យស្រឡាញ់គ្នាទៅវិញទៅមក។ ប៊ីម បន្តថា៖ «ឃ្លានេះ គឺចង់ឲ្យយើងម្នាក់ៗចេះអត់ធ្មត់គ្រប់បញ្ហា និងឧបសគ្គដែលកើតមាននិងឲ្យយើងចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ហើយកុំឲ្យយើងបាក់ទឹកចិត្តនៅពេលមានអ្វីកើតឡើងចំពោះយើង»។

យុវតីរូបនេះឲ្យដឹងថា ពីមុនមកនាងធ្លាប់ធ្លាក់ទឹកចិត្តចំពោះរឿងរ៉ាវក្នុងជីវិតរបស់នាង។ ប៉ុន្តែក្រោយពេលដែលនាងបានឈ្វេងយល់អំពីជីវិតរបស់សន្តិក្លារ៉ា អ្វីៗត្រូវបានផ្លាស់ប្តូរ។

ក្លៃ ប៊ីម៖ «មនុស្សយើងម្នាក់តែងតែមានបញ្ហានៅក្នុងជីវិតមិនថាតូចឬធំ យើង(អាច) ដោះស្រាយតាមសន្តិវិធី ហើយនឹងអធិដ្ឋាន ផ្ញើកិច្ចការទាំងអស់ទៅព្រះជាម្ចាស់»។

ក្រៅពីជីវិតរបស់សន្តិក្លារ៉ា យុវជនក៏សិក្សាបន្ថែមអំពីជីវិតរបស់លោកបូជាចារ្យវ៉ាំបុាំង ដែលបានបូជាជីវិតក្នុងសម័យសង្គ្រាមនៅក្នុងប្រទេសកម្ពុជា សក្ខីភាពរបស់បងស្រីម៉ារីដែលជាដូនជីកំពុងបម្រើការងារនៅព្រះសហគមន៍កោះរការ។ យុវជនទាំងនោះមកពីព្រះសហគមន៍ចំនួន៣ក្នុងខេត្តមណ្ឌលគិរី គឺ ប៊ូស្រា ដាក់ដាំ និងកែវសីមា៕

# លោកបូជាចារ្យដែលទទួលមុខងារ និងបេសកកម្មថ្មី



លោកឪពុក **លូកា បូឡេល្លី** បានចាកចេញពីប្រទេសកម្ពុជា ដើម្បីបំពេញមុខងារថ្មីនៅប្រទេសអ៊ីតាលីវិញ លោកបូជាចារ្យ លូកា បូឡេល្លី ជាក្រុមសាសនទូតគ្រឹះស្ថានរបស់សម្តេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស PIME លោកបានមកបម្រើព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០៧។

## សូមបងប្អូនអធិដ្ឋានសម្រាប់លោកបូជាចារ្យទាំងពីរអង្គ





លោកបូជាចារ្យ **ផាន បូរី** និងលោកបូជាចារ្យ **សែ សាត** បានចាកចេញពីប្រទេសកម្ពុជាកាលពីថ្ងៃទី១៣ កញ្ញា ២០១៩ ដើម្បីបន្តការសិក្សានៅប្រទេសបារាំង។ លោកបូជាចារ្យ ផាន បូរី សិក្សាផ្នែកច្បាប់ព្រះសហគមន៍ (Cannon Law) និងលោកបូជាចារ្យ សែ សាត សិក្សាអំពីផ្លូវវិញ្ញាណ។ ការសិក្សានេះ លោកទាំងពីរត្រូវចំណាយពេល៥ឆ្នាំនៅក្នុងប្រទេសបារាំង។ សូមបងប្អូនអធិដ្ឋានសម្រាប់លោកបូជាចារ្យទាំងពីរអង្គ។

RADIO VERITAS ASIA

# វិទ្យុវេរីតាស់អាស៊ីខេមរភាសា

## សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវេរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយវិទ្យុ FM នៅភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

លោកអ្នកអាចស្តាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ khmer.rvasia.org និង www.catholiccambodia.org
ឬលោកអ្នកអាច Follow @RVAkhmer ផ្លូវការរបស់យើងតាមរយៈ www.facebook.com/RVAKHMER/
និងតាមដានវីដេអូលើបណ្តាញ Youtube: www.youtube.com/RVAkhmer